# បដិច្ចសមុប្បាទន័យ

វគ្គសិក្សានៅសាលាសតិប្បដ្ឋានខេត្តបាត់ដំបង

បង្រៀនដោយ

លោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស**

រៀបរៀងដោយ

ខ្ញុំព្រះករុណា **ហាយ ចំរើន**

ពុទ្ធសករាជ ២៥៦០

# បដិច្ចសមុប្បាទន័យ

ពុទ្ធសករាជ ២៥៦០

វគ្គសិក្សានៅសាលាសតិប្បដ្ឋានខេត្តបាត់ដំបង

បង្រៀនដោយលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស

រៀបរៀងដោយ

ខ្ញុំព្រះករុណា ហាយ ចំរើន

# បដិច្ចសមុប្បាទវិភាគ

ទ្វេ បដិច្ចសមុប្បាទ បដ្ឋាននយភេទិនោ
វុត្តា តត្ថ នយា ហោន្តិ យេហិ បច្ចយសង្គហោ

បច្ច័យសង្គហៈនេះ កាលសំដែងទៅតាមទីតាំងហើយ
ក៏មានពីរន័យ គឺ បដិច្ចសមុប្បាទន័យ និងបដ្ឋានន័យ ។

សេចក្ដីនៃព្រះធម៌នេះ ខ្ញុំបាទដកស្រង់ចេញពីសៀវភៅអភិធម្មផ្លូវអាកាស

# អារម្ភកថា

ក្រោយពីបានរៀបរៀងហើយ ខ្ញុំបាទក៏យកទៅប្រគេនលោកម្ចាស់គ្រូ **អភិធម្មានន្ទោ ម៉ៅ ឯក** ជួយផ្ទៀងផ្ទាត់ នឹងឃើញថា មានសេចក្តីគួរសិក្សាបាន ទើបខ្ញុំបាទស្នើដល់បងឧបាសិកា រម្មណី (ហៅឧបាសិកា មុំ) ជួយរៀបចំបោះពុម្ពជាសៀវភៅ ប្រគេន និងចែកជូនដល់សព្រហ្មចារីសិក្សា ដើម្បីជាការនឹករឭកដល់គុណូបការៈរបស់ **លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាឧត្តម-សប្បុរស** ដែលលោកបានបង្រៀននៅសាលាសតិប្បដ្ឋាន ខេត្តបាត់ដំបង ក្នុងវស្សានរដូវ ពុទ្ធសករាជ ២៥៦០ ត្រូវនឹងឆ្នាំ ២០១៦ ។

សូមសាធុជន បានចម្រើនក្នុងកុសល ដែលជាបច្ច័យឱ្យដល់ព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

បាត់ដំបង, ថ្ងៃព្រហស្បតិ៍ ១២ កើត ខែអស្សុជ ព.ស ២៥៦០

# មាតិកាធម៌


| ឈ្មោះធម៌ | ទំព័រ |
|---|---|
| បដិច្ចសមុប្បាទន័យ និងលក្ខណាទិចតុក្កៈ | ១ |
| អង្គ ១២ តាមន័យព្រះបាលី | ១ |
| បដិច្ចសមុប្បាទមាន ៧ ន័យ | ២ |
| **អង្គទី ១ អវិជ្ជា** | ៤ |
| អធិប្បាយ បុញ្ញាភិសង្ខារ ជាដើម | ៥ |
| បច្ច័យ ២៤ ទាក់ទងនឹងអវិជ្ជា និងការអធិប្បាយ | ៦ |
| សេចក្តីបន្ថែមទំនាក់ទំនងនឹងអវិជ្ជា | ១១ |
| **អង្គទី ២ សង្ខារ** | ១២ |
| អបុញ្ញាភិសង្ខារ  បុញ្ញាភិសង្ខារ | ១៤ |
| អានេញ្ជាភិសង្ខារ | ១៦ |
| បច្ច័យ ២៤ ទាក់ទងនឹងសង្ខារ | ១៧ |
| **អង្គទី ៣ វិញ្ញាណ** | ១៧ |
| វិញ្ញាណជាបច្ច័យដល់នាម និងដល់រូប | ២០ |
| វិញ្ញាណជាបច្ច័យដល់នាមរូប | ២១ |
| បច្ច័យ ២៤ ជាមួយវិញ្ញាណ | ២២ |
| **អង្គទី ៤ នាមរូប** | ២៤ |
| បច្ច័យ ២៤ ជាមួយនាមរូប | ២៧ |
| **អង្គទី ៥ សឡាយតនៈ** | ២៩ |
| បច្ច័យ ២៤ ជាមួយសឡាយតនៈ | ៣១ |
| **អង្គទី ៦ ផស្សៈ** | ៣២ |

| | |
|---|---|
| បច្ច័យ ២៤ ទាក់ទងនឹងផស្សៈ | ៣៤ |
| **អង្គទី ៧ វេទនា** | ៣៥ |
| កាមតណ្ហាជាដើម | ៣៧ |
| បច្ច័យ ២៤ ទាក់ទងនឹងវេទនា | ៣៨ |
| **អង្គទី ៨ តណ្ហា** | ៣៩ |
| អធិប្បាយអំពីទិដ្ឋិ | ៤០ |
| ការផ្សេងគ្នារវាងតណ្ហា និងឧបាទាន | ៤២ |
| បច្ច័យ ២៤ ទាក់ទងនឹងតណ្ហា | ៤៣ |
| **អង្គទី ៩ ឧបាទាន** | ៤៤ |
| ទំនាក់ទំនងរវាងកម្មភព និងឧបបត្តិភព | ៤៥ |
| បច្ច័យ ២៤ ទាក់ទងនឹងឧបាទាន | ៤៦ |
| **អង្គទី ១០ ភព** | ៤៦ |
| ជាតិ ២ យ៉ាង | ៤៨ |
| បច្ច័យ ២៤ ទាក់ទងនឹងភព | ៤៨ |
| **អង្គទី ១១ ជាតិ** | ៤៨ |
| រយៈកាលនៃអាយុ ១០ ៧ ដង | ៥០ |
| បច្ច័យ ២៤ ទាក់ទងនឹងជាតិ | ៥២ |
| **អង្គទី ១២ ជរាមរណៈ** | ៥២ |
| ឈ្មោះនៃសេចក្ដីស្លាប់ | ៥៤ |

# បដិច្ចសមុប្បាទន័យ

**បដិច្ច** (អាស្រ័យ) **+ សំ** (ព្រម) **+ ឧប្បាទ** (កើត) = ធមិដែល អាស្រ័យគ្នាកើតឡើងព្រម មានន័យថា ធមិដែលជាហេតុ ឱ្យកើតផលតជាប់ គ្នាមិនដាច់ខ្សែ ទើបធ្វើឱ្យវិលវល់ក្នុងសង្សារវដ្ត ។

## លក្ខណាទិចតុក្កៈរបស់បដិច្ចសមុប្បាទ

**ជរាមរណាទីនំ ធម្មានំ បច្ចយលក្ខណោ :**

មានឧបការៈដល់បច្ចយុប្បន្នធមិទាំងឡាយ ដូចជា ជរា មរណៈ ជាដើម ជាលក្ខណៈ ។

**ទុក្ខានុពន្ធនរសោ :** មានការធ្វើឱ្យសត្វទាំងឡាយកើតក្នុងវដ្តៈរឿយៗ ជាកិច្ច ។

**កម្មគ្គបច្ចុបដ្ឋានោ :** ជាផ្លូវវិលវល់ក្នុងវដ្តៈដែលគួរខ្លាច ឬជាផ្លូវដើរមិនត្រូវ គឺ ជាផ្លូវវៀច និងជាផ្លូវផ្ទុយអំពីផ្លូវទៅកាន់ព្រះនិព្វាន ជាអាការប្រាកដ ។

**អាសវបទដ្ឋានោ :** មានអាសវៈ ជាហេតុជិត ។

បដិច្ចសមុប្បាទធមិ មានអង្គ ១២ កន្លែងខ្លះក៏ហៅថា ***ភវចក្រ*** មាន ន័យថា វិលទៅកាន់ភពផ្សេងៗ បានដល់ ភូមិទាំង ៣១ ហៅថា សង្សារវដ្ត ឬសង្សារទុក្ខ ។

អង្គ ១២ តាមបាលីសម្ដែងថា :

| | |
|---|---|
| **អវិជ្ជាបច្ចយា សង្ខារា** | អវិជ្ជាជាបច្ច័យឱ្យកើតសង្ខារ |
| **សង្ខារប្បច្ចយា វិញ្ញាណំ** | សង្ខារជាបច្ច័យឱ្យកើតវិញ្ញាណ |

| | |
|---|---|
| វិញ្ញាណប្បច្ចយា នាមរូបំ | វិញ្ញាណជាបច្ច័យឱ្យកើតនាមរូប |
| នាមរូបប្បច្ចយា សឡាយតនំ | នាមរូបជាបច្ច័យឱ្យកើតសឡាយតនៈ |
| សឡាយតនប្បច្ចយា ផស្សោ | សឡាយតនៈជាបច្ច័យឱ្យកើតផស្សៈ |
| ផស្សប្បច្ចយា វេទនា | ផស្សៈជាបច្ច័យឱ្យកើតវេទនា |
| វេទនាបច្ចយា តណ្ហា | វេទនាជាបច្ច័យឱ្យកើតតណ្ហា |
| តណ្ហាបច្ចយា ឧបាទានំ | តណ្ហាជាបច្ច័យឱ្យកើតឧបាទាន |
| ឧបាទានប្បច្ចយា ភវោ | ឧបាទានជាបច្ច័យឱ្យកើតភព |
| ភវប្បច្ចយា  ជាតិ | ភពជាបច្ច័យឱ្យកើតជាតិ |
| ជាតិប្បច្ចយា ជរាមរណំ | ជាតិជាបច្ច័យឱ្យកើតជរា និងមរណៈ |

សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ (ឯ) សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ រមែងកើតឡើងព្រម ។

## បដិច្ចសមុប្បាទ មាន ៧ ន័យ

ពោលដោយមាតិកា បដិច្ចសមុប្បាទ មាន ៧ ន័យ ដូចគាថាថា ៖

បឋមេហិ នយេ តត្ថ        វេទិយំ        ឧបលក្ខណំ
តិយទ្ធំ   ទ្វាទសង្គាមិ        វិសាការ        តិសន្ធិ   ច
ចតុសង្ខេបំ        តិវដ្ដំ        ទ្វេ មូលានីតិ សត្តធា ។

បឋមន័យ មានគ្រឿងកំណត់ដឹងដោយអាការ ៧ យ៉ាង គឺ
អទ្ធា ៣ , អង្គ ១២ , អាការ ២០ , សន្ធិ ៣ , សង្ខេប ៤ ,
វដ្ដៈ ៣ និង មូល ២ ។

តយោ អទ្ធា ( អទ្ធា ៣ ) គឺ កាល ៣ មានសេចក្ដីថា អវិជ្ជា និងសង្ខារ ចាត់ជា អតីតអទ្ធា , ជាតិ និងជរាមរណៈ ជាអនាគតអទ្ធា ចំណែកអង្គ ៨ ត្រង់កណ្ដាល ចាត់ជា បច្ចុប្បន្នអទ្ធា ។

ទ្វាទសង្គានិ ( គឺអង្គ ១២ ) បានដល់ អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព ជាតិ និងជរាមរណៈ ។រីឯ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ និងឧបាយាសៈ មិនរាប់ជាអង្គបដិច្ច-សមុប្បាទ ព្រោះធម៌ ៥ ប្រការនេះ ក៏កើតព្រមជាមួយជាតិ កាលបើមាន ជាតិហើយ រមែងមានទុក្ខសោកជាប្រចាំ និងមិនមែនជាហេតុដោយត្រង់ ដែលធ្វើឱ្យកើតវដ្តៈ ។

វីសតាការា ( អាការ ២០ ) បានដល់

-អតីតហេតុ ៥ ប្រការ : អវិជ្ជា សង្ខារ តណ្ហា ឧបាទាន ភព ។

-បច្ចុប្បន្នផល ៥ ប្រការ : វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ។

-បច្ចុប្បន្នហេតុ ៥ ប្រការ : តណ្ហា ឧបាទាន កម្មភព អវិជ្ជា សង្ខារ ។

-អនាគតផល ៥ ប្រការ : វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ។

តិសន្ធិ ( ការតភ្ជាប់ ៣ ) បានដល់ សង្ខារ និងវិញ្ញាណ ជាសន្ធិ ១ , វេទនា និងតណ្ហា ជាសន្ធិ ១ , ភព និងជាតិ ជាសន្ធិ ១ ។

ចតុសង្ខេបា ( សង្ខេប ៤ ) គឺ

-អវិជ្ជា សង្ខារ ជាសង្ខេប ១

-វិញ្ញាណ នាមរូប សឡាយតន ផស្សៈ វេទនា ជាសង្ខេប ១

-តណ្ហា ឧបាទាន ភព ជាសង្ខេប ១

-ជាតិ ជរាមរណៈ ជាសង្ខេប ១

តីណិ វដ្ដានិ ( វដ្ដៈ ៣ ) បានដល់

-អវិជ្ជា តណ្ហា ឧបាទាន ជាកិលេសវដ្ដៈ

-សង្ខារ ភព ( កម្មភព ) ជាកម្មវដ្ដៈ

-វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ភព (ឧបបត្តិភព) ជាតិ ជរាមរណៈ ជាវិបាកវដ្ដៈ ។

ទ្វេមូលានិ ( មូល ២ ) បានដល់ អវិជ្ជា និងតណ្ហា ។

## អង្គទី ១ អវិជ្ជា

**អវិជ្ជា** ជាបច្ច័យឱ្យកើតសង្ខារ គឺ សង្ខារជាបច្ចុប្បន្នធម៌ នឹងប្រាកដឡើង ក៏ព្រោះមានអវិជ្ជាជាបច្ច័យ ជាហេតុ ទើបពោលដោយខ្លីៗ ថា អវិជ្ជាជាហេតុ សង្ខារជាផល ។

### លក្ខណាទិចតុក្កៈរបស់អវិជ្ជា

-អញ្ញាណលក្ខណា មានការមិនដឹង ជាលក្ខណៈ

-សម្មោហនរសា មានការវង្វេង ជាកិច្ច

-ឆាទនបច្ចុបដ្ឋានា មានការបិទបាំងអារម្មណ៍មិនឱ្យឃើញតាមពិត ជាផល

-អាសវបទដ្ឋានា មានអាសវៈ ជាហេតុជិត ។

**អវិជ្ជា** អង្គធម៌ បានដល់ មោហចេតសិក ដែលមិនដឹងក្នុងធម៌ ៨ ប្រការគឺ មិនដឹងក្នុងអរិយសច្ចៈ ៤ , មិនដឹងខន្ធជាអតីតៈ ១ , មិនដឹងខន្ធជាអនាគត ១ , មិនដឹងខន្ធទាំងអតីតៈ និងអនាគត ១ និងមិនដឹងបដិច្ច-សមុប្បាទធម៌ ១ ។ ព្រោះអវិជ្ជា គឺ ការមិនដឹងនេះឯង ទើបជាបច្ច័យឱ្យកើតសង្ខារ ឱ្យកើតការតាក់តែងឡើង ដែលបានដល់បុញ្ញាភិសង្ខារ អបុញ្ញា-ភិសង្ខារ និងអនេញ្ជាភិសង្ខារ ។

**១-បុញ្ញាភិសង្ខារ :** ការតាក់តែងជាបុណ្យ អង្គធម៌បានដល់ ចេតនាក្នុងមហាកុសលចិត្ត ៨ ដួង និងចេតនាក្នុងរូបាវចរកុសលចិត្ត ៥ ដួង រួមជាចេតនា ១៣ ដួង ដែលជាហេតុតាក់តែងឱ្យកើតកុសលកម្ម ឱ្យបានបដិសន្ធិជាមនុស្ស ជាទេវតា ជារូបព្រហ្ម ។

**២-អបុញ្ញាភិសង្ខារ :** អង្គធម៌បានដល់ ចេតនាក្នុងអកុសលចិត្ត ១២ ដួង ដែលតាក់តែងឱ្យកើតបាប និងឱ្យបដិសន្ធិក្នុងអបាយភូមិទាំង ៤ ។

**៣-អនេញ្ជាភិសង្ខារ :** អង្គធម៌បានដល់ ចេតនាក្នុងអរូបាវចរ-កុសលចិត្ត ៤ ដួង ដែលតាក់តែងឱ្យកើតកុសលនេះ និងឱ្យផលបដិសន្ធិក្នុងអរូបព្រហ្ម ។ ទាំងនេះ ក៏ព្រោះអវិជ្ជាជាហេតុ ដូចពោលមកនោះឯង ។

ន័យម្យ៉ាងទៀត សង្ខារជាបច្ចយុប្បន្នធម៌របស់អវិជ្ជា ៣ ទៀត គឺ

**-កាយសង្ខារ :** ចេតនាដែលតាក់តែងកាយទុច្ចរិត ជាផលសម្រេចមកអំពីអកុសលចេតនា ១២ និងមហាកុសលចេតនា ៨ ដែលទាក់ទងនឹងផ្លូវកាយ ។

**-វចីសង្ខារ :** ចេតនាដែលតាក់តែងវចីទុច្ចរិត ជាផលសម្រេចមកអំពីអកុសលចេតនា ១២ និងមហាកុសលចេតនា ៨ ដែលទាក់ទងនឹងផ្លូវវាចា ។

**-ចិត្តសង្ខារ :** ចេតនាដែលតាក់តែងមនោទុច្ចរិត ជាផលសម្រេចមកអំពីអកុសលចេតនា ១២ និងលោកិយកុសលចេតនា ១៧ ទាក់ទងនឹងផ្លូវចិត្ត ។

រួមសង្ខារ ៣ ក្តី ឬសង្ខារទាំង ៦ ក្តី ក៏បានដល់ ចេតនា ២៩ ឬ កម្ម ២៩ នោះឯង ។ ឯលោកុត្តរកុសលចេតនា ឈ្មោះថា ជាបុណ្យក៏ពិត តែមិនចាត់ជាបុញ្ញាភិសង្ខារ ឬអានេញ្ជាភិសង្ខារឡើយ ព្រោះលោកុត្តរកុសល មិនមាននាទីធ្វើឱ្យកើតភពជាតិ តែមាននាទីទម្លាយភពជាតិ កាត់វដ្តៈប៉ុណ្ណោះ ។

តាមសុត្តន្តន័យ : អវិជ្ជា ជាបច្ច័យឱ្យកើតសង្ខារ ៣ ទៀត គឺ

**-កាយសង្ខារ :** បានដល់ ខ្យល់អស្សាសៈ និងបស្សាសៈ

**-វចីសង្ខារ** : បានដល់ វិតក្កៈ និងវិចារៈ

**-មនោសង្ខារ :** បានដល់ សញ្ញា វេទនា ឬចេតសិក ៥០ (វៀរវិតក្កៈ វិចារៈ)

ព្រោះអវិជ្ជា ទើបជាបច្ច័យឱ្យធ្វើកម្ម (ចេតនា ២៩ ) ដែលត្រូវវិលវល់ក្នុងសង្សារទុក្ខ មិនរួចចាកទុក្ខទៅបាន ។

## បច្ច័យ ២៤ ដែលទាក់ទងនឹងអវិជ្ជា

ក្នុងបទថា អវិជ្ជា ជាបច្ច័យដល់បុញ្ញាភិសង្ខារ បើពោលដោយបច្ច័យ

២៤ ក៏ប្រព្រឹត្តទៅដោយអំណាចបច្ច័យដូច្នេះ

ក-**អវិជ្ជាជាបច្ច័យដល់អបុញ្ញាភិសង្ខារ** បានដោយអំណាចបច្ច័យ ១៥ គឺ

| | | |
|---|---|---|
| ១.ហេតុប្បច្ច័យ | ២.អារម្មណប្បច្ច័យ | ៣.អធិបតិប្បច្ច័យ |
| ៤.អនន្តរប្បច្ច័យ | ៥.សមនន្តរប្បច្ច័យ | ៦.សហជាតប្បច្ច័យ |
| ៧.អញ្ញមញ្ញប្បច្ច័យ | ៨.សហជាតនិស្សយ... | ៩.បកតូបនិស្សយ... |
| ១០.អាសេវនប្បច្ច័យ | ១១.សម្បយុត្តប្បច្ច័យ | ១២.អត្ថិប្បច្ច័យ |
| ១៣.នត្ថិប្បច្ច័យ | ១៤.វិគតប្បច្ច័យ | ១៥.អវិគតប្បច្ច័យ |

ខ-**អវិជ្ជាជាបច្ច័យដល់បុញ្ញាភិសង្ខារ** បានដោយអំណាចបច្ច័យ ២ គឺ

១.អារម្មណប្បច្ច័យ ២.បកតូបនិស្សយប្បច្ច័យ

គ-**អវិជ្ជាជាបច្ច័យដល់អានេញ្ជាភិសង្ខារ** បាន ១ បច្ច័យ គឺ

១.បកតូបនិស្សយប្បច្ច័យ

## អធិប្បាយ

**១.ហេតុប្បច្ច័យ :** ហេតុ ៦ ជាបច្ច័យឱ្យកើតចិត្ត-ចេតសិក ក្នុងទីនេះ មោហៈជាហេតុប្បច្ច័យ , អកុសលចិត្ត ១២ ដួង និងចេតសិកប្រកប ជាបច្ចយុប្បន្នៈ ។

**២.អារម្មណប្បច្ច័យ :** អារម្មណ៍ ជាបច្ច័យឱ្យកើតចិត្ត-ចេតសិក គឺកាលនឹកដល់វត្ថុដែលខ្លួនពេញចិត្តក្តី ទាស់ចិត្តក្តី សង្ស័យ ឬធ្វើឱ្យចិត្តរាយ-មាយ អារម្មណ៍នេះឯង ដែលជាបច្ច័យធ្វើឱ្យកើតអកុសលចិត្ត ១២ ដួង និង

ចេតសិកប្រកប ជាអារម្មណប្បច្ចយុប្បន្នៈ ។

**៣.អធិបតិប្បច្ច័យ :** អារម្មណ៍ជាធំ ដ៏មានកម្លាំង ឬដោយការយកចិត្តទុកដាក់ជាពិសេស ជាបច្ច័យឱ្យកើតចិត្ត-ចេតសិក ជាអធិបតិប្បច្ច័យ ឱ្យកើតអកុសលចិត្ត ១២ ដួង និងចេតសិកប្រកប ជាអធិបតិប្បច្ចយុប្បន្នៈ ។

**៤.អនន្តរប្បច្ច័យ :** ចិត្តកើតជាប់តគ្នាមិនមានចន្លោះ រួមជាមួយមោហចេតសិក ដោយមុខនាទី អកុសលចិត្តក៏ជាជវនចិត្ត ជវនចិត្តនេះ ជាប្រក្រតីកើតជាប់តគ្នា ៧ ខណៈ ដូច្នោះ មោហចេតសិកក្នុងអកុសលជវនដួងទី ១ ក៏ជាអនន្តរប្បច្ច័យដល់មោហៈក្នុងអកុសលជវនទី ២... ៧ ដែលជាអនន្តរប្បច្ចយុប្បន្នៈ ។

**៥.សមនន្តរប្បច្ច័យ :** ក៏ដូចគ្នានឹងអនន្តរប្បច្ច័យ គ្រាន់តែបញ្ជាក់ឱ្យច្បាស់ជាងអនន្តរប្បច្ច័យ ។

**៦.សហជាតប្បច្ច័យ :** ធម៌ដែលកើតព្រមគ្នា ក្នុងទីនេះ មោហចេត-សិក ត្រូវកើតព្រមជាមួយអកុសលចិត្ត និងចេតសិកប្រកប ដូច្នោះ មោហ-ចេតសិក ក៏ជាសហជាតប្បច្ច័យ ឯអកុសលចិត្ត ១២ ដួង និងចេតសិកដែលប្រកប ជាសហជាតប្បច្ចយុប្បន្នៈ ។

**៧.អញ្ញមញ្ញប្បច្ច័យ :** ធម៌ដែលជួយឧបការៈដល់គ្នានឹងគ្នា មោហ-ចេតសិកក៏ឧបការៈដល់អកុសលចិត្ត និងចេតសិកប្រកបឱ្យកើតឡើង អកុ-សលចិត្ត និងចេតសិកដែលប្រកប ក៏ជួយឧបការៈដល់មោហចេតសិកឱ្យកើតឡើងដូចគ្នា ដូច្នោះ មោហចេតសិកជាអញ្ញមញ្ញប្បច្ច័យ អកុសលចិត្ត ១២ ដួង

និងចេតសិកប្រកប ជាអញ្ញមញ្ញប្បច្ចយុប្បន្នៈ ។

**៨.និស្សយប្បច្ច័យ :** ធម៌ជាទីអាស្រ័យ ក្នុងទីនេះ មោហៈជាទីអាស្រ័យនៃអកុសលចិត្ត និងចេតសិកប្រកប ។ ន័យម្យ៉ាងទៀត អកុសលចិត្ត និងចេតសិកដែលប្រកបនេះឯង ដែលអាស្រ័យមោហៈ ទើបប្រាកដឡើងបាន ដូច្នោះ មោហៈទើបជានិស្សយប្បច្ច័យ អកុសលចិត្ត ១២ ដួង និងចេតសិកប្រកប ជានិស្សយប្បច្ចយុប្បន្នៈ ។

**៩.ឧបនិស្សយប្បច្ច័យ :** ធម៌ជាទីអាស្រ័យដ៏មានកម្លាំង ក្នុងទីនេះ មោហៈ ជាទីអាស្រ័យដ៏មានកម្លាំងនៃអកុសលចិត្ត និងចេតសិកប្រកប ។ អកុសលចិត្ត និងចេតសិកប្រកប អាស្រ័យមោហៈដ៏មានកម្លាំង ទើបកើតឡើងបាន ដូច្នោះ មោហៈក៏ជាឧបនិស្សយប្បច្ច័យ អកុសលចិត្ត ១២ ដួង និងចេតសិកប្រកប ជាឧបនិស្សយប្បច្ចយុប្បន្នៈ ។

**១០.អាសេវនប្បច្ច័យ :** ធម៌ដែលសេពអារម្មណ៍ច្រើនខណៈតគ្នា ក៏សំដៅជវនចិត្ត ព្រោះក្នុងវិថីមួយៗ ជវនចិត្តរមែងកើតជាប់តគ្នា ៧ ខណៈ ដូច្នោះ មោហៈក្នុងអកុសលជវនដួងទី ១ ទើបជាអាសេវនប្បច្ច័យដល់មោហៈក្នុងអកុសលជវនទី ២ និងតៗ ទៅ រហូតដល់មោហៈក្នុងអកុសលជវនដួងទី ៧ ជាអាសេវនប្បច្ចយុប្បនៈ ។

**១១.សម្បយុត្តប្បច្ច័យ :** ធម៌ដែលប្រកបព្រមគ្នា មោហៈ រមែងប្រកបនឹងអកុសលចិត្ត និងចេតសិក ដូច្នោះ មោហៈ ក៏ជាសម្បយុត្តប្បច្ច័យដល់អកុសលចិត្ត ១២ ដួង និងចេតសិកប្រកប ជាសម្បយុត្តប្បច្ចយុប្បន្នៈ ។

**១២.អត្ថិប្បច្ច័យ :** ធម៌ដែលកំពុងមានជាបច្ច័យ គឺ មោហៈដែលមិនទាន់រលត់ទៅ កំពុងតាំងនៅ ជាអត្ថិប្បច្ច័យ , អកុសលចិត្ត ១២ ដួង និងចេតសិកប្រកប ជាអត្ថិប្បច្ចយុប្បន្នៈ ។

**១៣.នត្ថិប្បច្ច័យ :** ធម៌ដែលមិនមាន គឺ រលត់ទៅហើយ ក៏ជាបច្ច័យបាន មានន័យថា មោហៈក្នុងអកុសលជវនដួងទី ១ រលត់ទៅហើយ ទើបជានត្ថិប្បច្ច័យ ដល់មោហៈក្នុងអកុសលជវនដួងទី ២ ... ទី ៧ ដែលជានត្ថិប្បច្ចយុប្បន្នៈ ។

**១៤.វិគតប្បច្ច័យ :** ធម៌ដែលប្រាសទៅហើយ គឺ រលត់ទៅហើយនោះឯង ជាបច្ច័យ ដូចគ្នានឹងនត្ថិប្បច្ច័យ ។

**១៥.អវិគតប្បច្ច័យ :** ធម៌ដែលមិនទាន់ប្រាសទៅ គឺ មិនទាន់រលត់ទៅ ជាបច្ច័យ ដូចគ្នានឹងអត្ថិប្បច្ច័យនោះឯង ។

**ខ.អវិជ្ជា ជាបច្ច័យដល់បុញ្ញាភិសង្ខារ :** មាន ២ បច្ច័យ គឺ

**១.អារម្មណប្បច្ច័យ :** អារម្មណ៍ ជាបច្ច័យឱ្យកើតចិត្ត-ចេតសិក ក៏ដោយអំណាចមោហៈ ទើបមានអារម្មណ៍ជាប់ចិត្ត ពេញចិត្ត ក្នុងមនុស្ស-សម្បត្តិ ទេវសម្បត្តិ និងព្រហ្មសម្បត្តិ ដែលជាហេតុញ៉ាំងមហាកុសលឱ្យកើតឡើងប្រាថ្នាមនុស្សសម្បត្តិ ទេវសម្បត្តិ និងព្យាយាមក្នុងភាវនាជារូបាវចរ-កុសលកម្ម ដើម្បីបាននូវព្រហ្មសម្បត្តិ ដូច្នេះ ឈ្មោះថា មោហៈជាអារម្ម-ណប្បច្ច័យ , មហាកុសល និងរូបាវចរកុសល ជាអារម្មណប្បច្ចយុប្បន្នៈ ។

**២.បកតូបនិស្សយប្បច្ច័យ :** ធម៌ជាបច្ច័យ និងជាទីអាស្រ័យ ដ៏មាន

កម្លាំង ឬជាទីអាស្រ័យដ៏មានកម្លាំងដល់បច្ចយុប្បន្នធម៌ ក្នុងបទនេះមានន័យថា មោហៈជាបច្ច័យ ជាទីអាស្រ័យដ៏មានកម្លាំង ជួយឧបការៈឱ្យធ្វើកម្ម ឱ្យមានសេចក្ដីព្យាយាមក្នុងមហាកុសល និងរូបាវចរកុសល ដូច្នេះ មោហៈ ទើបជាបកតូបនិស្សយប្បច្ច័យ ឯមហាកុសល និងរូបាវចរកុសល ព្រមទាំងចេតសិកប្រកប ជាបកតូបនិស្សយប្បច្ចយុប្បន្នៈ ។

**គ.អវិជ្ជា ជាបច្ច័យដល់អានេញ្ជាភិសង្ខារ :** មាន ១ បច្ច័យ

ដោយអំណាចបកតូបនិស្សយប្បច្ច័យតែ ១ ប៉ុណ្ណោះ ក៏ទំនងដូចគ្នានឹងការប្រាថ្នាក្នុងរូបព្រហ្មសម្បត្តិ ដូច្នេះ មោហៈ ជាបកតូបនិស្សយប្បច្ច័យ ឯអរូបាវចរកុសល ជាបកតូបនិស្សយប្បច្ចយុប្បន្នៈ ។

## ការបំពេញបន្ថែមប្រការដែលទំនាក់ទំនងជាមួយអវិជ្ជា

ប្រការខ្លះដែលទំនាក់ទំនងនឹងអវិជ្ជា ដែលគប្បីជ្រាបបន្ថែមនោះ គឺ

**ក.អវិជ្ជា** គឺ មោហចេតសិក មានលក្ខណៈតែមួយ គឺ មិនដឹងហេតុផល តាមសេចក្ដីពិតក្នុងធម៌ទាំងពួង ។

**អវិជ្ជា** មាន ២ យ៉ាង មិនដឹងក្នុងការបដិបត្តិខុស ១ និងមិនដឹងការបដិបត្តិត្រូវ ១ ឬមិនដឹងធម៌ដែលជាសង្ខារ ១ និងធម៌ជាវិសង្ខារ ១ ។

**អវិជ្ជា** មាន ៣ គឺ មិនដឹងតាមពិតក្នុងវេទនា ៣ ។

**អវិជ្ជា** មាន ៤ គឺ មិនដឹងក្នុងអរិយសច្ចៈ ៤ ។

**អវិជ្ជា** មាន ៥ គឺ មិនទុក្ខទោសក្នុងគតិ ៥ គឺ និរយគតិ បេតគតិ តិរច្ឆានគតិ មនុស្សគតិ និងទេវគតិ ទើបវិលវល់នៅក្នុងកងទុក្ខ ។

**អវិជ្ជា** មាន ៦ គឺ មិនដឹងសេចក្តីពិតក្នុងអារម្មណ៍ទាំង ៦ ក្នុងវិញ្ញាណទាំង ៦ ថាមិនទៀង ជាទុក្ខ ជាអនត្តា ។

**ខ.អវិជ្ជា ជាមួយអរិយសច្ចះ**

**អវិជ្ជា** ជាទុក្ខសច្ចះ កើតព្រមជាមួយទុក្ខសច្ចះ ធ្វើទុក្ខសច្ចះឱ្យជាអារម្មណ៍ តែបិទបាំងមិនឱ្យឃើញទុក្ខសច្ចះ ។

**អវិជ្ជា** មិនមែនជាសមុទយសច្ចះ សង្គ្រោះចូលក្នុងសមុទយសច្ចះ ក៏មិនបាន តែអវិជ្ជាកើតរួមជាមួយសមុទយសច្ចះ ធ្វើសមុទយសច្ចះឱ្យជាអារម្មណ៍បាន តែបិទបាំងមិនឱ្យឃើញសមុទយសច្ចះ ។

**អវិជ្ជា** មិនមែនជានិរោធសច្ចះ មិនសង្គ្រោះចូលក្នុងនិរោធសច្ចះ មិនកើតជាមួយនិរោធសច្ចះ ធ្វើនិរោធសច្ចះឱ្យជាអារម្មណ៍ក៏មិនបាន និងទាំងមិនឃើញនូវនិរោធសច្ចះនោះ ។

**អវិជ្ជា** មិនមែនជាមគ្គសច្ចះ មិនសង្គ្រោះចូលក្នុងមគ្គសច្ចះ មិនកើតរួមនឹងមគ្គសច្ចះ ធ្វើមគ្គសច្ចះឱ្យជាអារម្មណ៍មិនបាន និងមិនដឹងមគ្គសច្ចះ ។

## អង្គទី ២ សង្ខារ

**សង្ខារ ជាបច្ច័យដល់វិញ្ញាណ** គឺ វិញ្ញាណប្រាកដឡើង ក៏ព្រោះមានសង្ខារជាបច្ច័យ ដែលមានលក្ខណាទិចតុក្កះ ដូច្នេះ ។

**-អភិសង្ខារណលក្ខណា** : មានការតាក់តែង ជាលក្ខណះ ។

**-អាយូហនរសា** : មានសេចក្តីព្យាយាមឱ្យបដិសន្ធិវិញ្ញាណកើតឡើង

ឬព្យាយាមឱ្យផល គឺ រូបក្ខន្ធ នាមក្ខន្ធកើតឡើង ជាកិច្ច ។

**-ចេតនា បច្ចុប្បដ្ឋានា** : តាំងចិត្តធ្វើឱ្យកើតសេចក្ដីសម្រេច ជាផល ។

**-អវិជ្ជា បទដ្ឋានា** : មានអវិជ្ជា ជាហេតុជិត ។

**សង្ខារ** កាលពោលក្នុងបទអវិជ្ជា ជាបច្ចយុប្បន្នធម៌របស់អវិជ្ជា បានដល់ចេតនា ២៩ ឬកម្ម ២៩។ ឯសង្ខារពោលក្នុងបទនេះ គឺ សង្ខារ ជាបច្ច័យជួយឧបការៈ ឱ្យកើតវិញ្ញាណ ក៏បានដល់ ចេតនា ២៩ ឬកម្ម ២៩ ដូចគ្នា ។

**វិញ្ញាណ** ជាបច្ចយុប្បន្នធម៌របស់សង្ខារ មាន ២ ន័យ គឺ តាមអភិ-ធម្មភាជនិយ (តាមន័យព្រះអភិធម្ម) ១ និងតាមសុត្តន្តភាជនិយ (តាមន័យព្រះសូត្រ) ១ ។

**តាមន័យព្រះអភិធម្ម** វិញ្ញាណ ដែលជាបច្ចយុប្បន្នធម៌របស់សង្ខារ បានដល់ ចិត្តទាំងអស់ (ចេតសិកប្រកបជាមួយចិត្តនោះៗ តាមសមគួរ) ព្រោះចិត្តកើតឡើងបាន ក៏ត្រូវមានសង្ខារជាបច្ច័យ គឺ ត្រូវមានការតាក់តែងឱ្យកើត ។

**តាមន័យព្រះសូត្រ** វិញ្ញាណ ជាបច្ចយុប្បន្នធម៌របស់សង្ខារ បានដល់ លោកិយវិបាកវិញ្ញាណ ៣២ គឺ អកុសលវិបាកចិត្ត ៧ , អហេតុកកុសល-វិបាកចិត្ត ៨ , មហាវិបាកចិត្ត ៨ និងមហគ្គតវិបាកចិត្ត ៩ ប៉ុណ្ណោះ ។

លោកិយវិបាកវិញ្ញាណ ៣២ ដែលជាបច្ចុយុប្បន្នៈរបស់សង្ខារ ចែកជា ២ ពួកគឺ

**ក្នុងបដិសន្ធិកាល** ឈ្មោះថា បដិសន្ធិវិញ្ញាណ បានដល់ បដិសន្ធិចិត្ត ១៩ ដួង ក្នុងចំនួនលោកិយវិបាកវិញ្ញាណ ៣២ នោះឯង ។

ក្នុងបវត្តិកាល ឈ្មោះថា បវត្តិវិញ្ញាណ បានដល់ លោកិយវិបាក ៣២ មួយពួកទៀត ដែលមិនបានធ្វើកិច្ចបដិសន្ធិ ភវង្គ ចុតិ ។

## អបុញ្ញាភិសង្ខារ

**១.អបុញ្ញាភិសង្ខារ** គឺ ចេតនាក្នុងអកុសលចិត្ត ១១ ដួង (វៀរឧទ្ធច្ចចេតនា) ជាបច្ច័យ ឱ្យបដិសន្ធិវិញ្ញាណជាបច្ចយុប្បន្នធម៌ក្នុងបដិសន្ធិកាល គឺ ឧបេក្ខា-សន្តីរណអកុសលវិបាក ១ ដួង ធ្វើកិច្ចបដិសន្ធិក្នុងអបាយភូមិទាំង ៤ ជាពួកទុគ្គតិអហេតុកបុគ្គល (ទុគ្គតិបុគ្គល) ។

**២.អបុញ្ញាភិសង្ខារ** គឺ ចេតនាក្នុងអកុសលចិត្ត ១២ ដួង ជាបច្ច័យ ឱ្យកើតបវត្តិវិញ្ញាណ ដែលជាបច្ចយុប្បន្នធម៌ គឺ អកុសលវិបាកចិត្ត ៧ ដួង បានដល់ អកុសលវិបាកចក្ខុវិញ្ញាណ... អកុសលវិបាកកាយវិញ្ញាណ , សម្បដិច្ឆន្នចិត្ត , សន្តីរណចិត្ត , តទាលម្ពណៈ ដែលដឹងអារម្មណ៍មិនល្អ រហូតដល់ការរក្សាអង្គភព (ភវង្គ) ផង ។

## បុញ្ញាភិសង្ខារ

**១.បុញ្ញាភិសង្ខារ** បានដល់ ចេតនាក្នុងមហាកុសលចិត្ត ជាទ្វិហេតុកឱមក្កដ្ឋៈ និងទ្វិហេតុកឱមកោមកៈ ជាបច្ច័យដល់បដិសន្ធិវិញ្ញាណ និងជាបច្ចយុប្បន្នធម៌ក្នុងបដិសន្ធិកាល គឺ ឧបេក្ខាសន្តីរណកុសលវិបាក ១ ដួង បដិសន្ធិជាមនុស្ស និងទេវតាជាន់ទាប ដែលមានភាពវិកលវិការ គ ថ្លង់ ឆ្កួត ជាដើម ហៅថា សុគតិអហេតុកបុគ្គល ។

**២.បុញ្ញាភិសង្ខារ** គឺ ចេតនាក្នុងមហាកុសល ជាតិហេតុកឱមក្កដ្ឋៈ , តិហេតុ-

កខិមកោមកៈ , ទ្វិហេតុកឧក្កដ្ឋកដ្ឋៈ និងទ្វិហេតុកឧក្កដ្ឋោមកៈ ជាបច្ច័យ ញ៉ាំងបដិសន្ធិវិញ្ញាណ ដែលជាបច្ចយុប្បន្នធម៌ ក្នុងបដិសន្ធិកាល គឺ មហាវិបាក-ញាណវិប្បយុត្តចិត្ត ៤ ដួង ឱ្យបដិសន្ធិក្នុងមនុស្ស និងទេវតា ដែលមិនមានបញ្ញាអំពីកំណើត ហៅថា ទ្វិហេតុកបុគ្គល ។

**៣.បុញ្ញាភិសង្ខារ** គឺ ចេតនាក្នុងមហាកុសល ដែលជាតិហេតុកឧក្កដ្ឋកដ្ឋៈ និងជាតិហេតុកឧក្កដ្ឋោមកៈ ជាបច្ច័យ ញ៉ាំងបដិសន្ធិវិញ្ញាណ ដែលជាបច្ចយុ-ប្បន្នធម៌នៅក្នុងបដិសន្ធិកាល គឺ មហាវិបាកញាណសម្បយុត្ត ៤ ដួង ដែលឱ្យបដិសន្ធិជាមនុស្ស និងទេវតា និងប្រកបដោយបញ្ញាអំពីកំណើត ដែលហៅថាតិហេតុកបុគ្គល ។

**៤.បុញ្ញាភិសង្ខារ** ទាំង ៣ ប្រការនេះ បានដល់ ចេតនាក្នុងមហាកុសល ៨ ដួង ជាបច្ច័យ ញ៉ាំងបវត្តិវិញ្ញាណជាបច្ចយុប្បន្នធម៌ ក្នុងបវត្តិកាល ដូច្នេះ

**ក.អហេតុកកុសលវិបាក ៨ ដួង** ឱ្យឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ សម្បដិច្ឆន្នៈ សន្តីរណៈ តទាលម្ពណៈ សុទ្ធតែល្អៗ ។

**ខ.មហាវិបាក ៨ ដួង** ធ្វើនាទីរក្សាអង្គភព (ភវង្គៈ) ផង ។

**-បុញ្ញាភិសង្ខារ** បានដល់ ចេតនាក្នុងរូបាវចរកុសលចិត្ត ៥ ដួង ជាបច្ច័យញ៉ាំងឱ្យបដិសន្ធិវិញ្ញាណ ដែលជាបច្ចយុប្បន្នធម៌ក្នុងបដិសន្ធិកាល គឺ រូបាវ-ចរវិបាកចិត្ត ៥ ដួង ឱ្យបដិសន្ធិក្នុងរូបព្រហ្ម ក៏ហៅថា តិហេតុកបុគ្គលដែរ ។

**-បុញ្ញាភិសង្ខារ** គឺ ចេតនាក្នុងរូបាវចរកុសលចិត្ត ៥ ដួង ជាបច្ច័យ ញ៉ាំងបវត្តិវិញ្ញាណ ដែលជាបច្ចយុប្បន្នធម៌ក្នុងបវត្តិកាល គឺ អហេតុកកុសលវិបាក-

ចិត្ត ៥ ដួង ឱ្យមានការឃើញ ការឮ សម្បដិច្ឆន្នៈ សន្តីរណៈ សុទ្ធតែល្អៗ និង ភវង្គ ។

## អានេញ្ជាភិសង្ខារ

**១.អានេញ្ជាភិសង្ខារ** គឺ ចេតនាក្នុងអរូបាវចរកុសលចិត្ត ៤ ដួង ជាបច្ច័យ ញុំាងបដិសន្ធិវិញ្ញាណដែលជាបច្ចយុប្បន្នធម៌ ក្នុងបដិសន្ធិកាល គឺ អរូបាវចរវិបាកចិត្ត ៤ ដួង ឱ្យបដិសន្ធិក្នុងអរូបព្រហ្ម ហៅថា តិហេតុកបុគ្គល ។

**២.អានេញ្ជាភិសង្ខារ** គឺ ចេតនាក្នុងអរូបាវចរកុសលចិត្ត ៤ ដួង ជាបច្ច័យ ញុំាងបវត្តិវិញ្ញាណ ដែលជាបច្ចយុប្បន្នធម៌ក្នុងបវត្តិកាល គឺ អរូបាវចរវិបាកចិត្ត ៤ ដួង ធ្វើភវង្គកិច្ច ។

<u>កំណត់ចំណាំ</u> :

ក្នុងបទ សង្ខារជាបច្ច័យដល់វិញ្ញាណនេះ សង្ខារ ៣ ដែលជាបច្ច័យឱ្យកើតវិញ្ញាណ ចែកចេញជាពីរ គឺ សង្ខារ ៣ ជាបច្ច័យដល់បដិសន្ធិវិញ្ញាណ បានដល់ ចេតនា ២៨ (វៀរឧទ្ធច្ចចេតនា) ព្រោះឧទ្ធច្ចចេតនា មិនអាចញុំាងផល គឺ បដិសន្ធិបាន , ចំណែកសង្ខារ ៣ ដែលជាបច្ច័យក្នុងបវត្តិវិញ្ញាណ បានដល់ ចេតនា ២៩ ។

វិញ្ញាណ ដែលជាបច្ចយុប្បន្នធម៌របស់សង្ខារ ចែកជា ២ ចំណែក គឺ បដិសន្ធិវិញ្ញាណ បានដល់ចិត្ត ១៩ ដួង និងបវត្តិវិញ្ញាណ បានដល់ លោកិយវិបាកវិញ្ញាណ ៣២ ។ លោកិយវិបាកវិញ្ញាណ ៣២ នោះ កើតក្នុងបវត្តិកាលតែម្យ៉ាង មាន ១៣ ដួង គឺ ទ្វិបញ្ចវិញ្ញាណ ១០ , សម្បដិច្ឆន្នចិត្ត

២ និងសន្តីរណចិត្ត ១ ។ ឯបដិសន្ធិវិញ្ញាណ ១៩ ដួង ក្រៅអំពីធ្វើបដិសន្ធិកិច្ច ក្នុងបដិសន្ធិកាលហើយ ក្នុងបវត្តិកាលក៏នៅកើតចិត្ត ១៩ ដួងនេះបាន ប៉ុន្តែ កើតឡើងធ្វើកិច្ចដទៃ មិនបដិសន្ធិកិច្ច ។

## បច្ច័យ ២៤ ទាក់ទងជាមួយសង្ខារ

ក្នុងបទ **សង្ខារ ជាបច្ច័យដល់វិញ្ញាណ** នេះ ក្នុងបច្ច័យ ២៤ ក៏ប្រព្រឹត្ត ទៅបានត្រឹមតែ ២ បច្ច័យ គឺ បកតូបនិស្សយប្បច្ច័យ ១ និងនានក្ខណិក-កម្មប្បច្ច័យ ១ ។

ន័យរបស់បកតូបនិស្សយប្បច្ច័យ បានពោលក្នុងខាងក្រោយហើយ ។

ចំណែកនានក្ខណិកកម្មប្បច្ច័យ សំដៅដល់ កម្ម ឬសង្ខារ គឺ ចេតនា ដែលកើតផ្សេងខណៈគ្នា (ចេតនាដែលរលត់ទៅហើយ) ជាបច្ច័យដល់នាម និងរូប ដែលកើតអំពីកម្មនោះៗ ដូច្នោះ ក្នុងទីនេះទើបបានដល់ ចេតនា ជា នានក្ខណិកកម្មប្បច្ច័យ ឯវិញ្ញាណ ជានានក្ខណិកកម្មប្បច្ចយុប្បន្នៈ ។

## អង្គទី ៣ វិញ្ញាណ

**វិញ្ញាណ ជាបច្ច័យដល់នាមរូប :**

### លក្ខណាទិចតុក្កៈរបស់វិញ្ញាណ

-**វិជាននលក្ខណំ** : មានការដឹងអារម្មណ៍ ជាលក្ខណៈ ។

-**បុព្វង្គមរសំ** : ជាប្រធាននៃចេតសិក និងកម្មជរូប ជាកិច្ច ។

-**បដិសន្ធិបច្ចុប្បដ្ឋានំ** : មានការបន្តរវាងភពចាស់ និងភពថ្មី ជាផល ។

-**សង្ខារបទដ្ឋានំ វា**

**វិត្ថារម្មណបទដ្ឋានំ** : មានសង្ខារ ៣ ជាហេតុ ឬមានវត្ថុ ៦ អារម្មណ៍ ៦ ជាហេតុជិត ។

ក្នុងបទមុន វិញ្ញាណ ជាបច្ចយុប្បន្នរបស់សង្ខារ មាន ២ ប្រភេទ គឺ

**-បដិសន្ធិវិញ្ញាណ** បានដល់ បដិសន្ធិចិត្ត ១៩ ដួង

**-បវត្តិវិញ្ញាណ** បានដល់ លោកិយវិបាកចិត្ត ៣២ ដួង

តែក្នុងបទថា វិញ្ញាណជាបច្ច័យ ដល់នាមរូប ក៏ចែកចេញជា ២ ដូចគ្នា គឺ

**ក-វិបាកវិញ្ញាណ** បានដល់ លោកិយវិបាកវិញ្ញាណ ៣២ ដួង ជាហេតុជិត ( អាសន្នការណំ ) ។

**ខ-កម្មវិញ្ញាណ** បានដល់ អកុសលចិត្ត ១២ និងលោកិយចិត្ត ១៧ ដែលសហគតជាមួយអកុសលចេតនា និងលោកិយចេតនាក្នុងអតីតភព ក៏គឺកម្មវិញ្ញាណ ២៩ ដួង នោះឯង ជាហេតុឆ្ងាយ ( ទូរការណំ ) ។

ចំណែក **នាមរូប** ដែលជាបច្ចយុប្បន្នធម៌របស់វិញ្ញាណ មានន័យដូច្នេះ គឺ **នាម** ក្នុងបទនេះ សំដៅដល់ ចេតសិក ប៉ុណ្ណោះ ។

**ក.តាមន័យព្រះអភិធម្ម** ដែលពោលមកហើយថា វិញ្ញាណ បានដល់ចិត្តទាំងអស់ ដូច្នេះ **នាម** គឺ សំដៅដល់ចេតសិកទាំង ៥២ ដួង ដែលប្រកបជាមួយចិត្តទាំងអស់ តាមសមគួរក្នុងចិត្តនោះ ៗ ។

**ខ.តាមន័យព្រះសូត្រ** ក៏វិញ្ញាណ បានដល់ លោកិយវិបាកវិញ្ញាណ ៣២ ដួង ដូច្នេះ ក្នុងបទនេះ **នាម** គឺ ចេតសិក បានដល់ ចេតសិក ៣៥ ដួង

ដែលប្រកបជាមួយលោកិយវិបាកវិញ្ញាណ ៣២ ប៉ុណ្ណោះ ។

**នាម** គឺ ចេតសិក ដែលប្រកបជាមួយបដិសន្ធិវិញ្ញាណ ១៩ ហៅថា **បដិសន្ធិនាម** (បដិសន្ធិចេតសិក) ។ ចេតសិកដែលកើតក្នុងបដិសន្ធិកាលនេះ អាស្រ័យកម្មវិញ្ញាណក្នុងអតីតភព និងបដិសន្ធិវិញ្ញាណក្នុងបច្ចុប្បន្នភពនេះឯង ជាបច្ច័យ ។

**នាម** គឺ ចេតសិក ដែលប្រកបជាមួយបវត្តិវិញ្ញាណ ៣២ ហៅថា **បវត្តិនាម** (បវត្តិចេតសិក) ។ ចេតសិកដែលកើតក្នុងបវត្តិកាលនេះ អាស្រ័យបវត្តិវិបាកវិញ្ញាណតែម្យ៉ាង ជាបច្ច័យ ។

**រូប** បានដល់ រូបរបស់សត្វ គឺ រូបទាំង ២៨ ន័យម្យ៉ាងទៀត សំដៅចំពោះកម្មជរូបដោយត្រង់ និងចិត្តជរូបដោយអម ប៉ុណ្ណោះ ។

**កម្មជរូប** ដែលកើតព្រមជាមួយបដិសន្ធិវិញ្ញាណ ១៥ (វៀរអរូប-បដិសន្ធិ) ហៅថា **បដិសន្ធិរូប** កម្មជរូបដែលកើតក្នុងបដិសន្ធិកាលនេះ អាស្រ័យកម្មវិញ្ញាណក្នុងអតីតភព និងបដិសន្ធិវិញ្ញាណក្នុងបច្ចុប្បន្ន ជាបច្ច័យ ។

**បវត្តិកម្មជរូប** ដែលកើតពីកម្មវិញ្ញាណ ២៥ (វៀរអរូបកម្មវិញ្ញាណ ៤) និងចិត្តជរូប ដែលកើតពីបវត្តិវិញ្ញាណ ១៨ (វៀរទ្វិបញ្ចវិញ្ញាណ ១០ និងអរូបវិបាកវិញ្ញាណ ៤) ទាំងពីរនេះ ហៅថា **បវត្តិរូប** ។ កម្មជរូប ដែលកើតក្នុងបវត្តិកាលនេះ អាស្រ័យកម្មវិញ្ញាណក្នុងអតីតភពតែម្យ៉ាង ជាបច្ច័យ , ចិត្តជរូប ដែលកើតក្នុងខណៈបដិសន្ធិកាលមិនមាន តែកើតឡើងក្នុងបវត្តិកាលបាន ដោយអាស្រ័យបវត្តិវិបាកវិញ្ញាណ ជាបច្ច័យ ។

សរុបមកថា រូបក្នុងបដិសន្ធិកាល មានតែកម្មជរូបតែម្យ៉ាង ឯរូបក្នុងបវត្តិកាល មានទាំងកម្មជរូប និងចិត្តជរូប ។

**វិញ្ញាណ ជាបច្ច័យដល់នាមរូប** ចែកតាមន័យបច្ច័យបាន ៣ ប្រការ គឺ វិញ្ញាណជាបច្ច័យដល់នាម ១ , វិញ្ញាណជាបច្ច័យដល់រូប ១ និងវិញ្ញាណជាបច្ច័យដល់នាមរូប ១ ។

## វិញ្ញាណជាបច្ច័យដល់នាម

**វិញ្ញាណជាបច្ច័យដល់នាម** ន័យដោយចំពោះ គឺ វិញ្ញាណ ជាបច្ច័យដល់ ចេតសិកតែម្យ៉ាង ដូច្នេះ

១.កម្មវិញ្ញាណ គឺ អរូបាវចរកុសលចិត្ត ៤ ដួង សហគតដោយអរូបចេតនាក្នុងអតីតភព ជាបច្ច័យដល់បដិសន្ធិនាម គឺ ចេតសិក ៣០ ដួង ដែលប្រកបជាមួយបដិសន្ធិវិញ្ញាណ ក្នុងចតុវោការភូមិ ៤ ក្នុងបដិសន្ធិកាល ។

២.វិបាកវិញ្ញាណ គឺ អរូបាវចរបដិសន្ធិវិញ្ញាណ ៤ ដួង ក្នុងបច្ចុប្បន្នភព ជាបច្ច័យដល់បដិសន្ធិនាម គឺ ចេតសិក ៣០ ដួង ដែលប្រកបជាមួយបដិសន្ធិចិត្តក្នុងចតុវោការភូមិ ៤ ក្នុងបដិសន្ធិកាល ។

៣. វិបាកវិញ្ញាណ គឺ អរូបាវចរវិបាកវិញ្ញាណ ៤ ដួង គឺ ភវង្គចិត្ត ជាបច្ច័យដល់បវត្តិនាម គឺ ចេតសិក ៣០ ដួង ដែលប្រកបជាមួយភវង្គចិត្ត ក្នុងចតុវោការភូមិ ៤ ក្នុងបវត្តិកាល ។

## វិញ្ញាណជាបច្ច័យដល់រូប

**វិញ្ញាណជាបច្ច័យដល់រូប** គឺ កម្មវិញ្ញាណ បានដល់ រូបាវចរបញ្ចម-

ជ្ឈានកុសលចិត្ត ដែលសហគតជាមួយចេតនាក្នុងសញ្ញាវិរាគភាវនាក្នុងអតីត-ភពជាបច្ច័យ ដល់កម្មជរូបក្នុងឯកវោការភូមិ គឺ អសញ្ញសត្តភូមិ ទាំងក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាល ។

## វិញ្ញាណជាបច្ច័យដល់នាមរូប

**វិញ្ញាណជាបច្ច័យដល់នាមរូប** គឺ វិញ្ញាណ ជាបច្ច័យឱ្យកើតនាម គឺ ចេតសិក និងរូប គឺ កម្មជរូប និងចិត្តជរូប ។

**១.កម្មវិញ្ញាណ** គឺ អកុសលចិត្ត ១១ , មហាកុសលចិត្ត ៨ , រូបាវចរកុសល ចិត្ត ៥ សរុប ២៤ ដួងនេះ ដែលសហគតជាមួយចេតនាក្នុងអតីតភព ជាបច្ច័យឱ្យកើតបដិសន្ធិនាម និងបដិសន្ធិរូប ក្នុងបញ្ចវោការភូមិ ២៦ ក្នុងបដិសន្ធិកាល ។

បដិសន្ធិនាម គឺ ចេតសិក ៣៥ ដែលប្រកបជាមួយបដិសន្ធិចិត្ត ១៥ ដួង ។

បដិសន្ធិរូប គឺ កម្មជរូប ដែលកើតព្រមជាមួយបដិសន្ធិចិត្ត ១៥ ដួង ។

**២.វិបាកវិញ្ញាណ** គឺ បដិសន្ធិវិញ្ញាណ ១៥ ដួង ក្នុងបច្ចុប្បន្នភព ជាបច្ច័យដល់បដិសន្ធិនាម គឺ ចេតសិក ៣៥ និងកម្មជរូប ដែលកើតព្រមជាមួយបដិសន្ធិចិត្តនោះ ក្នុងបញ្ចវោការភូមិ ២៦ ក្នុងបដិសន្ធិកាល ។

**៣.វិបាកវិញ្ញាណ** គឺ ភវង្គចិត្ត ១៥ ដួង ជាបច្ច័យដល់ បវត្តិនាម គឺ ចេតសិក ៣៥ និងបវត្តិរូប គឺ ចិត្តជរូប ក្នុងបញ្ចវោការភូមិ ២៦ ក្នុងបវត្តិកាល ។

**៤.វិបាកវិញ្ញាណ** គឺ សម្បដិច្ឆន្នចិត្ត ២ ដួង និងសន្តីរណចិត្ត ១ ដួង ជាបច្ច័យដល់បវត្តិនាម គឺ អញ្ញសមានាចេតសិក ១១ ដួង និងបវត្តិរូប គឺ ចិត្តជរូប ក្នុងបញ្ចវោការភូមិ ២៦ ក្នុងបវត្តិកាល ។

**៥.វិបាកវិញ្ញាណ** គឺ ទ្វិបញ្ចវិញ្ញាណ ១០ ជាបច្ច័យដល់បវត្តិនាម គឺ សព្វសាធារណចេតសិក ៧ ក្នុងបញ្ចវោការភូមិ ២៦ ក្នុងបវត្តិកាល ។

## បច្ច័យ ២៤ ជាមួយវិញ្ញាណ

ក្នុងបទ វិញ្ញាណជាបច្ច័យដល់នាមរូបនេះ បើពោលដោយបច្ច័យ ២៤ ក៏ប្រព្រឹត្តទៅដោយអំណាចបច្ច័យ ដូចតទៅ

**ក.វិញ្ញាណជាបច្ច័យដល់នាម** គឺ ចេតសិកតែម្យ៉ាង (ក្នុងចតុវោការ-ភូមិ) ដោយអំណាចបច្ច័យ ៩ បច្ច័យ គឺ

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.និស្សយប្បច្ច័យ

៤.វិបាកប្បច្ច័យ ៥.អាហារប្បច្ច័យ ៦.ឥន្ទ្រិយប្បច្ច័យ

៧.សម្បយុត្តប្បច្ច័យ ៨.អត្ថិប្បច្ច័យ ៩.អវិគតប្បច្ច័យ

**ខ.វិញ្ញាណជាបច្ច័យដល់រូប** គឺ ដល់កម្មជរូបតែម្យ៉ាង (ក្នុងឯកវោ-ការភូមិ) ដោយអំណាចបច្ច័យ ៤ បច្ច័យ គឺ

១.វិបាកប្បច្ច័យ ២.វិប្បយុត្តប្បច្ច័យ

៣.នត្ថិប្បច្ច័យ ៤.វិគតប្បច្ច័យ

**គ.វិញ្ញាណជាបច្ច័យដល់នាមរូប** (ក្នុងបញ្ចវោការភូមិ) ដោយអំណាច ៩ បច្ច័យ គឺ

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.និស្សយប្បច្ច័យ

៤.វិបាកប្បច្ច័យ ៥.អាហារប្បច្ច័យ ៦.ឥន្ទ្រិយប្បច្ច័យ

៧.វិប្បយុត្តប្បច្ច័យ ៨.អត្ថិប្បច្ច័យ ៩.អវិគតប្បច្ច័យ

ក្នុងបច្ច័យទាំងនេះ បច្ច័យណាបានអធិប្បាយហើយ មិនបានលើកយកមកអធិប្បាយទៀតទេ អធិប្បាយតែបច្ច័យដែលមិនទាន់បានអធិប្បាយប៉ុណ្ណោះ ។

**ក.វិបាកប្បច្ច័យ** : បានដល់ វិបាកនាមក្ខន្ធ ៤ ជាបច្ច័យដល់គ្នានឹងគ្នាទាំងជាបច្ច័យដល់រូប ដែលកើតព្រមជាមួយខ្លួន គឺ ជាបច្ច័យដល់នាម (ចេ-តសិក) និងរូប ដែលកើតព្រមជាមួយវិញ្ញាណនោះ ជាវិបាកបច្ចយុប្បន្នៈ ។

**ខ.អាហារប្បច្ច័យ** : បានដល់ អាហារទាំង ៤ ជាបច្ច័យដល់នាមរូបដែលកើតព្រមគ្នានោះ គឺ វិញ្ញាណជាអាហារប្បច្ច័យ , នាម គឺ ចេតសិកនិងរូប ដែលកើតឡើង ជាអាហារប្បច្ចយុប្បន្នៈ ។

**គ.ឥន្ទ្រិយប្បច្ច័យ** : បានដល់ បសាទរូប ៥ ជាបច្ច័យជួយឧបការៈដល់បញ្ចវិញ្ញាណ , រូបជីវិតិន្ទ្រិយ ជាបច្ច័យដល់ឧបាទិន្នករូប និងនាមឥន្ទ្រិយជាបច្ច័យដល់នាមរូប ដែលកើតព្រមជាខ្លួននោះឯង ដូច្នេះ ក្នុងទីនេះ វិញ្ញាណទើបជាឥន្ទ្រិយប្បច្ច័យ , នាមរូប ជាឥន្ទ្រិយប្បច្ចយុប្បន្នៈ ។

**ឃ.វិប្បយុត្តប្បច្ច័យ** : បានដល់ ធម៌ដែលមិនប្រកបជាមួយគ្នា ក្នុងលក្ខណៈ ៤ យ៉ាង គឺ ឯកុប្បាទៈ ឯកនិរោធៈ ឯកាលម្ពណៈ ឯកវត្ថុកៈ ដូច្នេះក្នុងទីនេះ វិញ្ញាណ ជាវិប្បយុត្តប្បច្ច័យ , រូបដែលកើតព្រមជាមួយចិត្តនោះ

ជាវិប្បយុត្តប្បច្ចយុប្បន្នៈ ។

## អង្គទី ៤ នាមរូប

នាម រូប ជាបច្ច័យដល់សឡាយតនៈ គឺ អាយតនៈក្នុង ៦ កើតឡើងបាន ព្រោះមាននាម និងរូប ជាបច្ច័យ ។

នាម ក្នុងទីនេះ បានដល់ ចេតសិក ដែលមានលក្ខណាទិចតុក្កៈ ដូច្នេះ

**-នមនលក្ខណំ** : មានការបង្អោនទៅកាន់អារម្មណ៍ ជាលក្ខណៈ ។

**-សម្បយោគរសំ** : មានការប្រកបជាមួយវិញ្ញាណ ដោយការកើតព្រមគ្នានោះឯង ជាកិច្ច ។

**-អវិនិព្ភោគបច្ចុបដ្ឋានំ** : មានការមិនបែកគ្នាជាមួយចិត្ត ជាផល ។

**-វិញ្ញាណបទដ្ឋានំ** : មានវិញ្ញាណ ជាហេតុជិត ។

រូប ក្នុងទីនេះ គឺ កម្មជរូប (ដោយត្រង់) ចិត្តជរូប (ដោយអម) លក្ខណាទិចតុក្កៈរបស់រូប :

**-រុប្បនលក្ខណំ** : មានការបែកធ្លាយ ជាលក្ខណៈ

**-វិកិរណរសំ** : មានការប្រាសចាកអំពីគ្នា (ជាមួយចិត្ត) ជាកិច្ច

**-អព្យាកតបច្ចុប្បដ្ឋានំ** : មានភាពជាអព្យាកតធម៌ ជាផល

**-វិញ្ញាណបទដ្ឋានំ** : មានវិញ្ញាណ ជាហេតុជិត ។

នាម គឺ ចេតសិក ដែលជាបច្ច័យដល់អាយតនៈនោះ បានដល់ចេតសិក ៣៥ ដែលប្រកបជាមួយលោកិយវិបាកវិញ្ញាណ ៣២ ប៉ុណ្ណោះ ។

រូប ដែលជាបច្ច័យដល់អាយតនៈ បានដល់ កម្មជរូប ប៉ុណ្ណោះ ។

**អាយតនៈ** ជាបច្ចយុប្បន្នៈរបស់នាមរូប បានដល់ **សឡាយតនៈ** គឺ អាយតនៈខាងក្នុង ៦ ហៅថា **អជ្ឈត្តិកាយតនៈ** មានចក្ខាយតនៈ សោតា-យតនៈ ឃានាយតនៈ ជីវ្ហាយតនៈ កាយាយតនៈ និងមនាយតនៈ ។

**អាយតនៈ** មានន័យថា ជាគ្រឿងតឱ្យកើតចិត្ត និងចេតសិក ជាគ្រឿងតឱ្យកើតវិថីចិត្ត ។

នាមរូប ជាបច្ច័យដល់សឡាយតនៈ ដូច្នេះ

១. ព្រោះកម្មជរូប គឺ ចក្ខុបសាទ ទើបមាន ចក្ខាយតនៈ

២. ព្រោះកម្មជរូប គឺ សោតបសាទ ទើបមាន សោតាយតនៈ

៣.ព្រោះមានកម្មជរូប គឺ ឃានបសាទ ទើបមាន ឃានាយតនៈ

៤. ព្រោះមានកម្មជរូប គឺ ជីវ្ហាបសាទ ទើបមាន ជីវ្ហាយតនៈ

៥. ព្រោះមានកម្មជរូប គឺ កាយបសាទ ទើបមាន កាយាយតនៈ

៦. ព្រោះមានចេតសិក ៣៥ ដែលប្រកបជាមួយនឹងលោកិយវិបាក-វិញ្ញាណ ៣២ ទើបមាន មនាយតនៈ

ដោយចំពោះ មនាយតនៈ មានវាទៈលើកឡើងមកថា

-អាចារ្យ និងដីកាចារ្យពួកខ្លះ ពោលថា មនាយតនៈនេះ បានដល់ លោកិយវិបាក ៣២ ។

-ភាសាដីកាចារ្យខ្លះ ពោលថា មនាយតនៈនេះ បានដល់ ភវង្គចិត្ត ១៩ ដួង ដោយអាងថា ភវង្គចិត្ត ជាតួមនោទ្វារ ជួយឧបការៈឱ្យផស្សៈ និង

វេទនាជាដើម ដូចក្នុងព្រះពុទ្ធតម្រាស់ថា មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ **មនោវិញ្ញាណំ តិណ្ណំ ផស្សោ ផស្សប្បច្ចយា វេទនា ។ល។** ប្រែថា មនោ-**វិញ្ញាណ** រមែងប្រាកដឡើងបាន ព្រោះអាស្រ័យ **មនោទ្វារ** និង **ធម្មារម្មណ៍** កាលធម៌ទាំង ៣ នេះប្រជុំគ្នាហើយ ក៏ ហៅថា **ផស្សៈ** ផស្សៈជាបច្ច័យដល់ វេទនា ។ល។

ម្យ៉ាងទៀត មានសេចក្ដីគួរពិចារណាថា ក្នុងបទមុនពោលថា វិញ្ញាណ ជាបច្ច័យដល់នាមរូប គឺ លោកិយវិបាកចិត្ត ជាបច្ច័យឱ្យកើតចេតសិក និង កម្មជរូប ។

ក្នុងបទនេះ គឺ នាមរូប ជាបច្ច័យដល់សឡាយតនៈ គឺ នាម បានដល់ ចេតសិកជាបច្ច័យដល់មនាយតនៈ បានដល់ លោកិយវិបាកវិញ្ញាណ ៣២ និង កម្មជរូប ដែលជាបច្ច័យដល់បញ្ចាយតនៈ (អាយតនៈ ៥) គឺ បសាទរូប ៥ ។

រួមសេចក្ដីមក គឺ បទមុន **វិញ្ញាណជាបច្ច័យដល់ចេតសិក** តែបទនេះ គឺ **ចេតសិកជាបច្ច័យដល់វិញ្ញាណ** ទើបមិនគួរសង្ស័យឡើយ ។

ក្នុងសេចក្ដីនេះ ព្រះមានព្រះភាគទ្រង់សម្ដែងយ៉ាងនេះ ក៏ដោយអំណាច នៃសហជាតប្បច្ច័យ គឺ ការកើតព្រមគ្នា កើតរួមគ្នាប្រការមួយ និងដោយ អំណាចនៃអញ្ញមញ្ញប្បច្ច័យ គឺ ការអាស្រ័យគ្នានឹងគ្នានៃធម៌ទាំងនោះ ប្រការ មួយ ។

ពោលគឺ **នាម** គឺ ចេតសិក និង **មនាយតនៈ** គឺ លោកិយវិបាក-វិញ្ញាណនោះ កើតព្រមគ្នា កើតជាមួយគ្នា ដូច្នេះ សូម្បីចេតសិកកើតរួមជា

មួយចិត្ត ឬថា ចិត្តកើតរួមជាមួយចេតសិក ក៏បានទាំង ២ យ៉ាង នេះពោល ដោយសហជាតប្បច្ច័យ ។

ពោលដោយអញ្ញមញ្ញប្បច្ច័យ ចិត្ត និងចេតសិក កើតព្រមគ្នា អាស្រ័យគ្នានឹងគ្នា ហើយឧបការៈដល់គ្នានឹងគ្នា គឺ ចេតសិកឧបការៈដល់ចិត្ត ចិត្តក៏ឧបការៈដល់ចេតសិក បានទាំង ២ យ៉ាង ដូចគ្នា ។

ចំណែក រូប បសាទរូប ៥ និងបញ្ចាយតនៈ ក៏ជារូបតែមួយនោះឯង តែបើពោលដោយសមុដ្ឋាន ហៅថា កម្មជរូប ។ បើមានបសាទរូប ទើបមានគ្រឿងត ដែលជាបច្ច័យឱ្យកើតចិត្ត និងចេតសិក និងវិថីចិត្តបាន ។

## បច្ច័យ ២៤ ទាក់ទងជាមួយនាមរូប

ក្នុងបទ **នាមរូបជាបច្ច័យដល់សឡាយតនៈ** ពោលដោយបច្ច័យ ២៤ មានបច្ច័យ ១៦ គឺ

| | | |
|---|---|---|
| ១.ហេតុ | ២.សហជាត | ៣.អញ្ញមញ្ញ |
| ៤.និស្សយ | ៥.បុរេជាត | ៦.បច្ឆាជាត |
| ៧.កម្ម | ៨.វិបាក | ៩.អាហារ |
| ១០.ឥន្ទ្រិយ | ១១.ឈាន | ១២.មគ្គ |
| ១៣.សម្បយុត្ត | ១៤.វិប្បយុត្ត | ១៥.អត្ថិ |
| ១៦.អវិគត | | |

ក្នុង ១៦ បច្ច័យ សូមលើកយកបច្ច័យដែលមិនទាន់អធិប្បាយមកប៉ុណ្ណោះ ។

**-បុរេជាតប្បច្ច័យ** គឺ រូបធមិដែលកើតមុន ជាបច្ច័យដល់នាមធមិ មានន័យថា វត្ថុ ៦ ជាបច្ច័យដល់វិញ្ញាណធាតុ ៧ ក្នុងបវត្តិកាល (វត្ថុបុរេ-ជាតប្បច្ច័យ) ។ អារម្មណ៍ ៥ ជាបច្ច័យដល់បញ្ចវិញ្ញាណវិថី (អារម្មណបុរេ-ជាតប្បច្ច័យ) ។

ទាំង ២ នេះ ដោយអំណាចនៃបុរេជាតប្បច្ច័យ ។

**-បច្ឆាជាតប្បច្ច័យ** គឺ នាមធមិ (ចិត្តចេតសិក) ជាបច្ច័យដល់រូបធមិ ដែលកើតមុន ។

ដូចជា ចក្ខុវិញ្ញាណ និងចេតសិក ៧ ដួង ដែលកើតក្រោយនោះឯង ជាបច្ច័យដល់ចក្ខុបសាទ (ចក្ខាយតនៈ) ដែលកើតមុន ឱ្យតាំងនៅបានដោយល្អ ។

**-កម្មប្បច្ច័យ** គឺ ចេតនាដែលកើតរួមជាមួយចិត្ត ជាបច្ច័យដល់នាមរូបនោះ ដែលកើតព្រមជាមួយខ្លួន ហៅថា សហជាតកម្មប្បច្ច័យ ។

ចេតនា ដែលកើតក្នុងខណៈផ្សេងគ្នា (គឺរលត់ទៅហើយ) ជាបច្ច័យដល់នាមរូបដែលកើតឡើងព្រោះកម្មនោះ ហៅថា នានក្ខណិកកម្មប្បច្ច័យ ។

ទាំង ២ នេះ ដោយអំណាចនៃកម្មប្បច្ច័យ ។

**-ឈានប្បច្ច័យ** គឺ អង្គឈាន ៥ (វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតា) ក៏ជាបច្ច័យដល់នាមរូប ក្នុងខណៈកើតព្រមគ្នា ។

តួយ៉ាងដូចជា អង្គឈាន ៥ ក្នុងខណៈបដិសន្ធិចិត្ត ជាបច្ច័យដល់បដិ-សន្ធិចេតសិក និងកម្មជរូប ពោលគឺ ក្នុងខណៈបដិសន្ធិកាល , ចំណែកក្នុង

បវត្តិកាល ក៏បានដល់ អង្គឈាន ៥ ក្នុងវិបាកចិត្ត ជាបច្ច័យដល់វិបាកចិត្ត ចេតសិក និងចិត្តជរូប ។

-មគ្គប្បច្ច័យ គឺ អង្គមគ្គ ៩ (បញ្ញា វិតក្កៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ វីរិយៈ សតិ ឯកគ្គតា និង ទិដ្ឋិ) ជាបច្ច័យ ដល់នាមរូបដែលកើតព្រមគ្នា ។

ដូចជា អង្គមគ្គក្នុងសហេតុកបដិសន្ធិចិត្ត ១៧ ក្នុងបដិសន្ធិកាល ជាបច្ច័យដល់សហេតុកបដិសន្ធិចិត្ត ១៧ ចេតសិកប្រកប និងកម្មជរូប ។

ចំណែកក្នុងបវត្តិកាល អង្គមគ្គក្នុងសហេតុកវិបាកចិត្ត ១៧ ជាបច្ច័យដល់សហេតុកវិបាកចិត្ត ១៧ ចេតសិកប្រកប និងចិត្តជរូប ។

## អង្គទី ៥ សឡាយតនៈ

**សឡាយតនៈជាបច្ច័យដល់ផស្សៈ** ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ។

### លក្ខណាទិចតុក្កៈរបស់សឡាយតនៈ

**អាយតនលក្ខណំ** : មានការប៉ះខ្ទប់ ឬមានការធ្វើវដ្តៈឱ្យវែងឆ្ងាយ មិនមានទីបំផុត ជាលក្ខណៈ ។

**ទស្សនរសំ វា ទស្សនាទិរសំ** : មានការប្រកាន់ក្នុងអារម្មណ៍របស់ខ្លួន ជាកិច្ច ឬមានការឃើញជាដើម ជាកិច្ច ។

**វត្ថុត្ថរភាវបច្ចុបដ្ឋានំ** : មានសភាពជាវត្ថុ ជាទ្វារ របស់វិញ្ញាណ-

ធាតុ ៧ តាមសមគួរដល់អារម្មណ៍ ជាផល ។

**នាមរូបបទដ្ឋាន** : មានចេតសិក និងរូប ជាហេតុជិត ។

ក្នុងបទមុន អជ្ឈត្តិកាយតនៈ ៦ ជាបច្ចយុប្បន្នធម៌ តែក្នុងបទនេះ សឡាយតនៈដែលជាបច្ច័យដល់ផស្សៈ ក៏បានដល់ អជ្ឈត្តិកាយតនៈ ៦ ដូចគ្នា គឺ

១.ចក្ខុសម្ផស្សៈ កើតមានព្រោះ ចក្ខាយតនៈជាបច្ច័យ
២.សោតសម្ផស្សៈ កើតមានព្រោះ សោតាយតនៈជាបច្ច័យ
៣.ឃានសម្ផស្សៈ កើតមានព្រោះ ឃានាយតនៈជាបច្ច័យ
៤.ជិវ្ហាសម្ផស្សៈ កើតមានព្រោះ ជិវ្ហាយតនៈជាបច្ច័យ
៥.កាយសម្ផស្សៈ កើតមានព្រោះ កាយាយតនៈជាបច្ច័យ
៦.មនោសម្ផស្សៈ កើតមានព្រោះ មនាយតនៈជាបច្ច័យ

ផស្សៈទាំង ៦ បានដល់ ផស្សៈចេតសិក ក្នុងលោកិយវិបាកវិញ្ញាណ ៣២ ប៉ុណ្ណោះ គឺ ផស្សៈ ៥ ក្នុងទ្វិបញ្ចវិញ្ញាណ ១០ , ចំណែកមនោសម្ផស្សៈ បានដល់ ផស្សៈក្នុងលោកិយវិបាកវិញ្ញាណ ២២ ដ៏សេស ។

ធម្មជាតិដែលប៉ះខ្ទប់ គឺ ផស្សៈ មានន័យថា ត្រូវមានធម៌ ៣ ប្រជុំគ្នា គឺ អារម្មណ៍ វត្ថុ និងវិញ្ញាណ ទើបជា ផស្សៈ ។ ដូចក្នុងនិទានវគ្គបាលី សំយុត្តនិកាយ ថា

ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ។បេ។

ចក្ខុវិញ្ញាណ រមែងប្រាកដឡើងព្រោះអាស្រ័យចក្ខុបសាទ ប៉ះខ្ទប់ជាមួយរូបារម្មណ៍ ការប្រជុំធមិ ៣ ប្រការ គឺ ចក្ខុបសាទ រូបារម្មណ៍ និង ចក្ខុវិញ្ញាណ នេះឯងឈ្មោះថា **ផស្សៈ** ។ល។

មនោវិញ្ញាណ រមែងប្រាកដឡើង ព្រោះអាស្រ័យភវង្គចិត្ត ប៉ះខ្ទប់ជាមួយធម្មារម្មណ៍ ការប្រជុំធមិទាំង ៣ គឺ ភវង្គចិត្ត ធម្មារម្មណ៍ និង មនោវិញ្ញាណ នេះឯងឈ្មោះថា **ផស្សៈ** ។

សឡាយតនៈជាបច្ច័យដល់ផស្សៈ បានក្នុងកាមភូមិ រូបភូមិ និង អរូបភូមិ

-ក្នុងកាមភូមិ ១១ មានអជ្ឈត្តិកាយតនៈទាំង ៦ ក៏ជាបច្ច័យដល់ផស្សៈ គ្រប់ទាំង ៦ ។

-ក្នុងរូបភូមិ ១៥ (វៀរអសញ្ញសត្តភូមិ ១) មានអជ្ឈត្តិកាយតនៈ ៣ គឺ ចក្ខាយតនៈ សោតាយតនៈ និងមនាយតនៈ ទើបមានផស្សៈ ៣ ដែរ ។

-ក្នុងអសញ្ញសត្តភូមិ មិនមានអជ្ឈត្តិកាយតនៈ ដូច្នេះ ក៏មិនមាន ផស្សៈ ។

-ក្នុងអរូបភូមិ ៤ មានអជ្ឈត្តិកាយតនៈ ១ គឺ មនាយតនៈ ទើប មានផស្សៈត្រឹមតែមួយ គឺ មនោសម្ផស្សៈ ។

## បច្ច័យ ២៤ ទាក់ទងជាមួយសឡាយតនៈ

សឡាយតនៈ ដែលទំនាក់ទំនងជាមួយបច្ច័យ ២៤ មានដូចតទៅ ។

**-ចក្ខាយតនៈ** ជាបច្ច័យដល់ ចក្ខុសម្ផស្សៈ

| | | |
|---|---|---|
| -សោតាយតនៈ | ជាបច្ច័យដល់ | សោតសម្ផស្សៈ |
| -ឃានាយតនៈ | ជាបច្ច័យដល់ | ឃានសម្ផស្សៈ |
| -ជិវ្ហាយតនៈ | ជាបច្ច័យដល់ | ជិវ្ហាសម្ផស្សៈ |
| -កាយាយតនៈ | ជាបច្ច័យដល់ | កាយសម្ផស្សៈ |

ដោយបច្ច័យ ៦ បច្ច័យ គឺ

| | | |
|---|---|---|
| ១.និស្សយ | ២.បុរេជាត | ៣.ឥន្ទ្រិយ |
| ៤.វិប្បយុត្ត | ៥.អត្ថិ | ៦.អវិគត |
| -មនាយតនៈ | ជាបច្ច័យដល់ | មនោសម្ផស្សៈ |

ដោយបច្ច័យ ៩ បច្ច័យ គឺ

| | | |
|---|---|---|
| ១.សហជាត | ២.អញ្ញមញ្ញ | ៣.និស្សយ |
| ៤.វិបាក | ៥.អាហារ | ៦.ឥន្ទ្រិយ |
| ៧.សម្បយុត្ត | ៨.អត្ថិ | ៩.អវិគត |

ក្នុងបច្ច័យទាំងអស់នេះ ក៏បានអធិប្បាយហើយ ។

## អង្គទី ៦ ផស្សៈ

### ផស្សៈ ជាបច្ច័យដល់វេទនា

### លក្ខណាទិចតុក្កៈរបស់ផស្សៈ

ផុស្សនលក្ខណោ : មានការប៉ះខ្ទប់អារម្មណ៍ ជាលក្ខណៈ

សង្ឃដ្ដនរសោ : មានការប្រមូលចិត្ត និងអារម្មណ៍ ជាកិច្ច

**សង្គតិបច្ចុបដ្ឋានោ** : មានការប្រជុំព្រមនូវ វត្ថុ អារម្មណ៍ និងវិញ្ញាណ ជាផល

**សឡាយតន បទដ្ឋានោ :** មានអជ្ឈត្តិកាយតនៈ ៦ ជាហេតុជិត ។

ក្នុងបទថា ផស្សៈ ជាបច្ច័យដល់វេទនា ក៏បានដល់ ផស្សៈ ៦ នោះឯង គឺ

-វេទនាកើតឡើង ព្រោះចក្ខុសម្ផស្សៈជាបច្ច័យ គឺ **ចក្ខុសម្ផស្សជាវេទនា**

-វេទនាកើតឡើង ព្រោះសោតសម្ផស្សៈជាបច្ច័យ គឺ **សោតសម្ផស្សជាវេទនា**

-វេទនាកើតឡើង ព្រោះឃានសម្ផស្សៈជាបច្ច័យ គឺ **ឃានសម្ផស្សជាវេទនា**

-វេទនាកើតឡើង ព្រោះជីវ្ហាសម្ផស្សៈជាបច្ច័យ គឺ **ជីវ្ហាសម្ផស្សជាវេទនា**

-វេទនាកើតឡើង ព្រោះកាយសម្ផស្សៈជាបច្ច័យ គឺ **កាយសម្ផស្សជាវេទនា**

-វេទនាកើតឡើង ព្រោះមនោសម្ផស្សៈជាបច្ច័យ គឺ **មនោសម្ផស្សជាវេទនា**

ធម្មជាតិដែលសោយអារម្មណ៍ ធម្មជាតិនោះ ឈ្មោះថា វេទនា ។ ការដឹងអារម្មណ៍ ឬការសោយអារម្មណ៍នោះ ឈ្មោះថា **វេទនា** ដោយលក្ខណៈនៃការសោយអារម្មណ៍ មាន ៣ គឺ សុខវេទនា ទុក្ខវេទនា និងអទុក្ខមសុខវេទនា ។ បើពោលដោយឥន្ទ្រិយ ក៏មាន ៥ គឺ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ និងឧបេក្ខិន្ទ្រិយ ។

ពោលតាមទ្វារ គឺ អាស្រ័យផ្លូវកើតរបស់វេទនា តាមន័យបដិច្ច-សមុប្បាទ ក្នុងទីនេះ មាន ៦ គឺ វេទនាកើតតាមទ្វារចក្ខុ សោតៈ ឃានៈ ជីវ្ហា កាយ និងទ្វារចិត្ត ។

វេទនា ដែលកើតតាមចក្ខុទ្វារ ហៅថា **ចក្ខុសម្ផស្សជាវេទនា** ... **ជីវ្ហាសម្ផស្សជាវេទា** ទាំង ៤ នេះ ប្រកបដោយឧបេក្ខាវេទនា តែម្យ៉ាង ។

**វេទនា** កើតតាមផ្លូវកាយ ហៅថា **កាយសម្ផស្សជាវេទនា** នោះ ជាសុខវេទនា ឬទុក្ខវេទនា ណាមួយក្នុង ២ យ៉ាងនេះ ប៉ុណ្ណោះ គឺ បើកាយបានសម្ផស្សនឹងឥដ្ឋផោដ្ឋព្វារម្មណ៍ គឺ អារម្មណ៍ជាទីប្រាថ្នា ក៏ជាសុខវេទនា , បើកាយប៉ះខ្ទប់នឹងអនិដ្ឋផោដ្ឋព្វារម្មណ៍ គឺ អារម្មណ៍មិនជាទីប្រាថ្នា ក៏ជាទុក្ខវេទនា ។

ចំណែកវេទនាផ្លូវចិត្ត ហៅថា **មនោសម្ផស្សជាវេទនា** នោះ កាលសោយអារម្មណ៍ដែលល្អ ក៏ជាសោមនស្សវេទនា , បើសោយអារម្មណ៍មិនល្អ ក៏ជាទោមនស្សវេទនា , បើសោយអារម្មណ៍ជាកណ្តាលៗ ក៏ជាឧបេក្ខាវេទនា ។

វេទនាទាំង ៦ ដែលពោលក្នុងបទនេះ សំដៅដល់វេទនាដែលប្រកបនឹងលោកិយវិបាកវិញ្ញាណ ៣២ ប៉ុណ្ណោះ គឺ ចិត្តដែលជាបច្ចយុប្បន្នធម៌របស់សង្ខារ ។ លោកិយវិបាកវិញ្ញាណ ៣២ នេះ ក៏មានវេទនាកើតរួមត្រឹមតែ ៤ គឺ សុខវេទនា ទុក្ខវេទនា សោមនស្សវេទនា និងឧបេក្ខាវេទនា មិនមានទោមនស្សវេទនា ។

ផស្សៈ និងវេទនា ជាចេតសិក និងកើតរួមជាមួយចិត្ត សូម្បីផ្សេងគ្នា ក៏ជាបច្ច័យដល់គ្នានឹងគ្នាបាន ដោយអំណាចសហជាតបច្ច័យ និងអញ្ញមញ្ញ-បច្ច័យ ទំនងដូចគ្នាជាមួយចិត្ត និងចេតសិក ដូចពោលមកហើយ ។

## បច្ច័យ ២៤ ទាក់ទងនឹងផស្សៈ

**ក្នុងផស្សៈជាបច្ច័យដល់វេទនា** នេះ ពោលដោយបច្ច័យ ២៤ ក៏ប្រព្រឹត្ត

ទៅ ដោយអំណាច ៨ បច្ច័យ គឺ

| | | |
|---|---|---|
| ១.សហជាត | ២.អញ្ញមញ្ញ | ៣.និស្សយ |
| ៤.វិបាក | ៥.អាហារ | ៦.សម្បយុត្ត |
| ៧.អត្ថិ | ៨.អវិគត | |

## អង្គទី ៧ វេទនា

### វេទនា ជាបច្ច័យដល់ តណ្ហា

### លក្ខណាទិចតុក្កៈរបស់វេទនា

**-អនុភវនលក្ខណា** : មានការសោយអារម្មណ៍ ជាលក្ខណៈ

**-វិសយរសសម្ភោគរសា:** មានការសោយរសរបស់អារម្មណ៍ ជាកិច្ច

**-សុខទុក្ខបច្ចុបដ្ឋានា** : មានសេចក្ដីសុខ និងទុក្ខ ជាផល

**-ផស្សបទដ្ឋានា** : មានផស្សៈ ជាហេតុជិត ។

តណ្ហា កើតឡើងព្រោះវេទនាជាបច្ច័យ គឺ តណ្ហា ជាបច្ចយុប្បន្នធម៌របស់វេទនានោះ បានដល់ លោភចេតសិក មួយដួងប៉ុណ្ណោះ ។

កាលបើមានសុខវេទនា ក៏មានការជាប់ចិត្តក្នុងសុខនោះ និងមានសេចក្ដីប្រាថ្នាឱ្យសេចក្ដីសុខនោះស្ថិតនៅអស់កាល ឬប្រាថ្នាឱ្យបាននូវសេចក្ដីសុខនោះកាន់តែក្រៃលែងឡើង ទើបបានឈ្មោះថា សុខវេទនា ជាបច្ច័យដល់តណ្ហា សេចក្ដីនេះក៏ឃើញបានងាយ ព្រោះសត្វទាំងឡាយរមែងស្អប់ខ្ពើមទុក្ខប្រាថ្នាសុខដូចគ្នា ។

កាលបើមានទុក្ខវេទនាហើយ ក៏ជាបច្ច័យឱ្យកើតតណ្ហា គឺ មានសេចក្តីប្រាថ្នានឹងឱ្យទុក្ខនោះវិនាសទៅ ហើយប្រាថ្នាឱ្យកើតសេចក្តីសុខជំនួស ដូច្នេះ ទើប បានឈ្មោះថា ទុក្ខវេទនា ជាបច្ច័យឱ្យកើតតណ្ហា ។

កាលមានឧបេក្ខាវេទនាហើយ ក៏ជាបច្ច័យដល់តណ្ហា ព្រោះគិតថា សូម្បីមិនមែនជាសុខ មិនមែនជាទុក្ខ តែក៏ប្រាថ្នាមិនឱ្យមានទុក្ខមកបៀតបៀន ប្រាថ្នាឱ្យតាំងនៅជាឧបេក្ខាយ៉ាងនេះរឿយៗ រហូតទៅ ដូច្នេះ ឧបេក្ខាវេទនា ទើបជាបច្ច័យដល់តណ្ហា ដូច្នេះឯង ។

តណ្ហានេះ មានសំដែងទុកច្រើនន័យ ដូចជា

**១.ពោលដោយអារម្មណ៍** តណ្ហា គឺ សេចក្តីត្រេកអរចង់បានអារម្មណ៍ ៦ គឺ

| | | |
|---|---|---|
| -រូបតណ្ហា | ជាប់ជំពាក់ក្នុង | រូបារម្មណ៍ |
| -សទ្ទតណ្ហា | ជាប់ជំពាក់ក្នុង | សទ្ទារម្មណ៍ |
| -គន្ធតណ្ហា | ជាប់ជំពាក់ក្នុង | គន្ធារម្មណ៍ |
| -រសតណ្ហា | ជាប់ជំពាក់ក្នុង | រសារម្មណ៍ |
| -ផោដ្ឋព្វតណ្ហា | ជាប់ជំពាក់ក្នុង | ផោដ្ឋព្វារម្មណ៍ |
| -ធម្មតណ្ហា | ជាប់ជំពាក់ក្នុង | ធម្មារម្មណ៍ |

**២-ពោលដោយការប្រព្រឹត្តទៅ** គឺ កាលបើមានសេចក្តីជាប់ជំពាក់ក្នុងអារម្មណ៍ទាំង ៦ នោះហើយ ក៏មានអាការប្រព្រឹត្តទៅ ៣ យ៉ាង ហៅថា កាមតណ្ហា ភវតណ្ហា និងវិភវតណ្ហា យ៉ាងដូច្នេះ

**ក.កាមតណ្ហា :** ជាសេចក្តីពេញចិត្ត ជាប់ជំពាក់ក្នុងអារម្មណ៍ ៦ ដែលទាក់ទងនឹងកាមគុណ តែមិនប្រកបដោយសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។

**ខ.ភវតណ្ហា :** ជាសេចក្តីពេញចិត្ត ជាប់ជំពាក់ក្នុងអារម្មណ៍ ៦ ដែលប្រកបដោយការឃើញ ដូចតទៅនេះ

១).ជាប់ចិត្តក្នុងកាមភព ការបានកើតជាមនុស្ស ជាទេវតា

២).ជាប់ចិត្តក្នុងរូបភព ការបានកើតជារូបព្រហ្ម

៣).ជាប់ចិត្តក្នុងអរូបភព ការបានកើតជាអរូបព្រហ្ម

៤).ជាប់ចិត្តក្នុងឈានសមាបត្តិ ការបានរូបឈាន និងអរូបឈាន

៥).ជាប់ចិត្តក្នុងតួខ្លួន គឺ ឃើញថា សត្វទាំងឡាយមានតួខ្លួន និងតួខ្លួនមិនសូន្យទៅណា សូម្បីនឹងស្លាប់ក៏ដោយ តែខ្លួនជាមនុស្ស ក៏នឹងកើតជាមនុស្ស ខ្លួនជាសត្វអ្វី ក៏នឹងទៅកើតជាសត្វនោះទៀត មិនមានការប្រែប្រួល ព្រោះឃើញថា ទៀង ដែលជាការឃើញខុស ហៅថា សស្សត្តទិដ្ឋិ (ក្នុងសត្តន្តមហាវគ្គអដ្ឋកថា) ។

**គ-វិភវតណ្ហា :** ជាសេចក្តីត្រេកអរ ជាប់ជំពាក់ក្នុងអារម្មណ៍ ៦ ដែលប្រកបដោយឧច្ឆេទទិដ្ឋិ គឺ មានការឃើញថា វត្ថុទាំងឡាយក្នុងលោកមានជាតួខ្លួន តែថា ខ្លួននោះមិនអាចនឹងតាំងនៅរហូតបាន នឹងត្រូវសោះសូន្យទៅទាំងអស់ សូម្បីការធ្វើទាំងឡាយ មិនថាជាកម្មល្អ ឬអាក្រក់ ក៏សូន្យទៅដូចគ្នា ការប្រាថ្នានេះ ហៅថា វិភវតណ្ហា ។

ក្នុង ២ ប្រការខាងលើ ក៏បានដល់ មួយពួកជាឧច្ឆេទទិដ្ឋិ ឃើញថា

សូន្យ មួយពួកទៀតជាសស្សតទិដ្ឋិ ឃើញថាទៀង ចំណែកមួយពួកក៏ជាប់ជំពាក់ក្នុងវត្ថុកាម ដែលមិនបាននឹកគិតដល់រឿងសូន្យ ឬក៏ទៀងឡើយ ។

**៣-ពោលដោយពិស្តារ :** តណ្ហាដោយពិស្តារ មាន ១០៨ គឺ អារម្មណ៏របស់តណ្ហាមាន ៦ និងអាការប្រព្រឹត្តទៅរបស់តណ្ហាមាន ៣ ទើបជាតណ្ហា (៦ គុណនឹង ៣) = ១៨ ។ តណ្ហា ១៨ មានទាំងខាងក្នុង ១៨ ខាងក្រៅ ១៨ ក៏ជា ៣៦ ។ តណ្ហាទាំង ៣៦ បានទាំង ៣ កាល គឺ អតីត ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ ទើបរួមជាតណ្ហា ១០៨ ។

វេទនាជាបច្ច័យដល់តណ្ហា នេះ ដោយចំពោះសម្រាប់អ្នកមានកិលេសប៉ុណ្ណោះ ចំណែកបុគ្គលអស់អាសវកិលេសហើយ វេទនាក៏ជាបច្ច័យដល់តណ្ហាមិនបាន ។ ក្នុងមជ្ឈិមបណ្ណាសកអដ្ឋកថា សំដែងថា សេចក្តីពេញចិត្តក្នុងការចម្រើនសមថៈ និងវិបស្សនា ក៏ហៅថា ធម្មតណ្ហា ដូចសាធកបាលីពោលថា **ធម្មរាគេន ធម្មនន្ទិយាតិ បទទ្វយេហិ សមថវិបស្សនាសុ ឆន្ទរាគោ វុត្តោ** ប្រែថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ដល់សេចក្តីត្រេកអរជាប់ជំពាក់ក្នុងការចម្រើនសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ដោយ ២ បទថា **ធម្មរាគះ ធម្មនន្ទិ** មានន័យថា ឆន្ទៈ រាគៈ ដែលកើតឡើងក្នុងសមថភាវនា និងវិបស្សនាភាវនា ឈ្មោះថា ធម្មតណ្ហា ។

## បច្ច័យ ២៤ ទាក់ទងនឹងវេទនា

វេទនាជាបច្ច័យដល់តណ្ហា ប្រព្រឹត្តទៅបានដោយ ១ បច្ច័យ ប៉ុណ្ណោះ គឺ បកតូបនិស្សយប្បច្ច័យ ។

## អង្គទី ៨ តណ្ហា

## តណ្ហាជាបច្ច័យដល់ឧបាទាន

## លក្ខណាទិចតុក្កៈរបស់តណ្ហា

**-ហេតុលក្ខណា :** ជាហេតុនៃទុក្ខទាំងពួង ជាលក្ខណៈ

**-អភិនន្ទនរសា :** មានការត្រេកអរពេញចិត្តក្នុងអារម្មណ៍ ភូមិ ភព ជាកិច្ច

**-អតិត្តិភាវបច្ចុបដ្ឋានា :** មានការមិនឆ្អែតក្នុងអារម្មណ៍ផ្សេងៗ ជាផល

**-វេទនាបទដ្ឋានា :** មានវេទនា ជាហេតុជិត ។

តណ្ហា ៣ ឬ ៦ ឬ ១០៨ ជាបច្ច័យដល់ឧបាទាន ។

ឧបាទាន ជាបច្ចយុប្បន្នរបស់តណ្ហា បានដល់ ឧបាទាន ៤ គឺ កាមុ-បាទាន ទិដ្ឋុបាទាន សីលព្វតុប្បាទាន និងអត្តវាទុប្បាទាន មានការអធិប្បាយដូចតទៅនេះ

**១.កាមុបាទាន** ការជាប់ជំពាក់ដោយប្រកាន់មាំក្នុងវត្ថុកាមទាំង ៦ មានរូបារម្មណ៍ជាដើម អង្គធម៌ បានដល់ លោភចេតសិក ។

**២.ទិដ្ឋុបាទាន** ការជាប់ជំពាក់ដោយប្រកាន់មាំក្នុងការឃើញខុស មាននិយតមិច្ឆាទិដ្ឋិ ៣ , មិច្ឆាទិដ្ឋិ ៦២ , អន្តគ្គាហិកទិដ្ឋិ ១០ អង្គធម៌ បានដល់ ទិដ្ឋិចេតសិក ដែលក្រៅពី សីលព្វតទិដ្ឋិ និងសក្កាយទិដ្ឋិ ។

**៣.សីលព្វតុបាទាន** ការជាប់ជំពាក់ដោយប្រកាន់មាំក្នុងការបដិបត្តិខុស មានការបដិបត្តិវត្តគោ និងសុនខជាដើម អង្គធម៌ គឺ សីលព្វតទិដ្ឋិ ។

**៤.អត្តវាទុបាទាន** ការជាប់ជំពាក់ដោយប្រកាន់មាំក្នុងខន្ធ ៥ ជារបស់ខ្លួន និងរបស់អ្នកដទៃថា ជាតួខ្លួន ជាសត្វ បុគ្គល ជាយើង ជាគេ អង្គធម៌ បានដល់ សក្កាយទិដ្ឋិ ។

ក្នុងប្រកាទី ១ **កាមុបាទាន** ការជាប់ជំពាក់ដោយប្រកាន់មាំក្នុងវត្ថុកាមទាំង ៦ នោះ ដែលហៅថា កាមុបាទាន ៦ បានដល់ រូបកាមុបាទាន , សទ្ទកាមុបាទាន , គន្ធកាមុបាទាន , រសកាមុបាទាន , ផោដ្ឋព្វកាមុបាទាន និងធម្មកាមុបាទាន ។

ក្នុងប្រការទី ២ **ទិដ្ឋុបាទាន** ការជាប់ជំពាក់ដោយប្រកាន់មាំក្នុងការឃើញខុស គឺ

**ក-និយតមិច្ឆាទិដ្ឋិ :** ទីខ្លះក៏ហៅថា មិច្ឆត្តនិយតៈ មាន ៣ គឺ

១).**អហេតុកទិដ្ឋិ** មានកាឃើញថា សត្វទាំងឡាយដែលកំពុងប្រព្រឹត្តទៅ មិនអាស្រ័យហេតុណាមួយឡើយ ( មិនជឿហេតុ អធិច្ចសមុប្បន្និកទិដ្ឋិ ២) ។

**២.នត្ថិកទិដ្ឋិ** មានការឃើញថា សត្វទាំងឡាយធ្វើអ្វីៗ ផលដែលនឹងបានទទួល មិនមាន ( មិនជឿផល ឧច្ឆេទទិដ្ឋិ ៧) ។

**៣.អកិរិយទិដ្ឋិ** មានការឃើញថា សត្វទាំងឡាយធ្វើអ្វីៗ មិនសម្រេចជាការធ្វើ គឺ បុណ្យ-បាប មិនមាន ( មិនជឿទាំងហេតុ-ផល សស្សតទិដ្ឋិ ៤)

**ខ-មិច្ឆាទិដ្ឋិ ៦២** ចែកបានចំណែកធំ ២ គឺ បុព្វន្តកប្បិកទិដ្ឋិ ១៨ និង អបរន្តកប្បិកទិដ្ឋិ ៤៤ ។

<u>បុព្វន្តកប្បិកទិដ្ឋិ មិនជឿហេតុក្នុងអតីតៈ ១៨ គឺ</u>

-សស្សតទិដ្ឋិ ៤ ឃើញថា អត្តា និងលោកទៀង ( អកិរិយទិដ្ឋិ)

-ឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ ៤ ឃើញថា អត្តា និងលោកទៀងខ្លះ មិនទៀងខ្លះ ។

-អន្តានន្តិកទិដ្ឋិ ៤ ឃើញថា លោកមានទីបំផុត និងមិនមានទីបំផុត ។

-អមរាវិក្ខេបទិដ្ឋិ ៤ មានការឃើញមិនឱ្យស្លាប់ខ្លួន នឹងឃើញថាមែនក៏មិនមែន នឹងឃើញថាមិនមែន ក៏មិនមែន ។

-អធិច្ចសមុប្បន្និកទិដ្ឋិ ២ ឃើញថា អត្តា និងលោកកើតឡើងឯងៗ មិនមានហេតុ ( អហេតុកទិដ្ឋិ) ។

<u>អបរន្តកប្បិកទិដ្ឋិ មិនជឿផលក្នុងអនាគត មាន ៤៤ គឺ</u>

-សញ្ញីវាទទិដ្ឋិ ១៦ ឃើញអត្តាមិនវិនាស ស្លាប់ហើយមានសញ្ញា ។

-អសញ្ញីវាទទិដ្ឋិ ៨ ឃើញអត្តាមិនវិនាស ស្លាប់ហើយមិនមានសញ្ញា ។

-នេវសញ្ញីនាសញ្ញីវាទ ៨ ឃើញអត្តាមិនវិនាស ស្លាប់ហើយមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

-ឧច្ឆេទទិដ្ឋិ ៧ ឃើញថា ស្លាប់ហើយសូន្យ ( នត្ថិកទិដ្ឋិ) ។

-ទិដ្ឋធម្មនិព្វានវាទទិដ្ឋិ ៥ ឃើញថា ព្រះនិព្វានមានក្នុងបច្ចុប្បន្ន ( គឺកាមគុណ ៥ ជាព្រះនិព្វាន , បឋមឈាន , ទុតិយឈាន , តតិយឈាន , ចតុត្ថឈាន ជាព្រះនិព្វាន) ។

<u>អន្តគ្គាហិកទិដ្ឋិ មាន ១០</u> គឺ មានការមិនជឿកម្ម និងផលរបស់កម្ម

ដែលផ្ទុយគ្នានឹងកម្មស្សកតាបញ្ញា ដែលឃើញថា សត្វមានកម្មជារបស់ខ្លួន ។

-នត្ថិ ទិន្នំ ឃើញថា ការធ្វើទានមិនមានផល ។

-នត្ថិ យិដ្ឋំ ឃើញថា ការបូជាផ្សេងៗ មិនមានផល ។

-នត្ថិ ហុតំ ឃើញថា ការបដិសណ្ឋារៈផ្សេងៗ មិនមានផល ។

-នត្ថិ សុកតទុក្កតានំ កម្មានំ ផលំ វិបាកោ ឃើញថា ការធ្វើល្អ និងធ្វើអាក្រក់ មិនមានផល ។

-នត្ថិ អយំ លោកោ ឃើញថា លោកនេះមិនមាន ( អ្នកមកកើតមិនមាន) ។

-នត្ថិ បរោ លោកោ ឃើញថា លោកខាងមុខមិនមាន ( អ្នកត្រូវទៅកើត មិនមាន) ។

-នត្ថិ មាតា ឃើញថា ការធ្វើល្អ-អាក្រក់ចំពោះមាតា មិនមាន ។

-នត្ថិ បិតា ឃើញថា ការធ្វើល្អ-អាក្រក់ចំពោះបិតា មិនមាន ។

-នត្ថិ សត្តា ឱបបាតិកា ឃើញថា សត្វដែលជាឱបបាតិកកំណើត គឺសត្វនរក ប្រេត មនុស្ស ទេវតា ព្រហ្ម មិនមាន ។

-នត្ថិ លោកេ សមណព្រាហ្មណា សម្មាបដិបន្នា ឃើញថា សមណ-ព្រាហ្មណ៍ដែលបដិបត្តិត្រូវក្នុងលោក មិនមាន ។

**ក្នុងប្រការទី ៣ សីលព្វតុបាទាន :**

ដែលប្រព្រឹត្តវត្តគោ វត្តសុនខ ជាដើមនោះ ព្រោះយល់ខុសថា យើងជាកូនបំណុល មិនមានប្រាក់ មិនអាចនឹងស្វែងរកប្រាក់បាន តែបើធ្វើខ្លួនឱ្យ

ម្ចាស់បំណុលប្រើ ក៏រមែងដោះបំណុលបាន យ៉ាងណា តែយើងបានធ្វើបាបកម្ម ទុកមកច្រើនហើយ បើមិនធ្វើខ្លួនឱ្យលំបាកដូចសត្វតិរច្ឆានទេ ក៏មិនអាចរួច ចាកបាបកម្មបាន ដូច្នោះ ទើបធ្វើខ្លួនឱ្យលំបាក ហើយប្រព្រឹត្តដូចជាគោ ដូច ជាសុនខ ដូច្នេះ ។

ក្នុងប្រការទី ៤ អត្តវាទុបាទាន ជាប់ជំពាក់ដោយការប្រកាន់មាំថា ជាតួខ្លួន គឺ ការប្រកាន់ដោយសក្កាយទិដ្ឋិនោះឯង មាន ២០ គឺ

-រូបក្ខន្ធ ឃើញថា រូបជាខ្លួន ខ្លួនមានរូប រូបនៅក្នុងខ្លួន ខ្លួន នៅក្នុងរូប ។ វេទនា , សញ្ញា , សង្ខារ និងវិញ្ញាណក្ខន្ធ ក៏ន័យដូចគ្នា ។

បុគ្គលទូទៅ វៀរព្រះអរិយបុគ្គលចេញ រមែងមានសក្កាយទិដ្ឋិទាំង អស់ ទើបសក្កាយទិដ្ឋិ ជាទិដ្ឋិសាម័ញ្ញ និងសក្កាយទិដ្ឋិនោះឯង ជាហេតុដល់ មិច្ឆាទិដ្ឋិទាំងឡាយ ។

## ការផ្សេងគ្នារវាងតណ្ហា និងឧបាទាន

ក្នុងវិភាវិនីដីកាថា **ឯត្ថ ច ទុព្វលតណ្ហា នាម ពលវតិ ឧបាទានំ** ប្រែ ថា ក្នុងទីនេះ តណ្ហាដែលមានកម្លាំងខ្សោយ ហៅថា តណ្ហា , តណ្ហាដែលមាន កម្លាំងខ្លាំង ហៅថា ឧបាទាន ។ ន័យម្យ៉ាងទៀតថា **បរិយេសនទុក្ខមូលំ តណ្ហា អារក្ខមូលំ ឧបាទានំ អយមេតេសំ វិសេសោ** ប្រែថា តណ្ហា មាន ទុក្ខក្នុងការស្វែងរកជាមូល , ឧបាទាន មានទុក្ខក្នុងការរក្សាជាមូល ។

តណ្ហា គឺ សេចក្ដីពេញចិត្តក្នុងអារម្មណ៍ ដែលខ្លួនបានប្រសព្វជាដំបូង ឧបាទាន គឺ ការជាប់ជំពាក់ក្នុងអារម្មណ៍ដែលខ្លួនបានជួបនោះរឿយៗ ។

តណ្ហា គឺ សេចក្តីប្រាថ្នាចង់បានក្នុងអារម្មណ៍ដែលខ្លួនបានជួបជាដំបូង ឧបាទាន គឺ ការប្រកាន់មាំក្នុងអារម្មណ៍ដែលខ្លួនបានមកហើយ ដោយមិនព្រលែងចេញ ។

ទើបមានការឧបមាទុកថា តណ្ហា ដូចជាដើមឈើនៅតូចៗ ដកចេញបានងាយ , ឧបាទាន ដូចជាដើមឈើធំ រមែងនឹងលំបាកដក ព្រោះឫសកែវរឹងមាំនោះឯង ។

**អប្បិច្ឆតាគុណ** គឺ សេចក្តីប្រាថ្នាតិច ដែលជាបដិបក្ខដល់តណ្ហា ធ្វើតណ្ហាឱ្យមានកម្លាំងខ្សោយចុះ ។

**សន្តុដ្ឋិគុណ** គឺ សេចក្តីសន្តោស ក៏ជាបដិបក្ខដល់ឧបាទាន បានដល់មានសេចក្តីពេញចិត្តស្មើក្នុងរបស់ដែលខ្លួនមាន ពេញចិត្តស្វែងរកដែលគួរដល់កម្លាំងរបស់ខ្លួនដោយសុចរិត សេចក្តីសន្តោសនេះ ពិតជាគុណចំពោះខ្លួន និងដល់អ្នកដទៃយ៉ាងច្រើន ។

## បច្ច័យ ២៤ ទាក់ទងនឹងតណ្ហា

ក-តណ្ហាជាបច្ច័យដល់កាមុបាទាន : ដោយអំណាចឧបនិស្សយបច្ច័យតែម្យ៉ាងប៉ុណ្ណោះ ។

ខ-តណ្ហាជាបច្ច័យដល់ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តវាទុបាទាន ដោយអំណាច ៧ បច្ច័យ គឺ

| | | |
|---|---|---|
| ១.ហេតុ | ២.សហជាត | ៣.អញ្ញមញ្ញ |
| ៤.និស្សយ | ៥.សម្បយុត្ត | ៦.អត្ថិ |

៧.អវិគត

## អង្គទី ៩ ឧបាទាន

### ឧបាទានជាបច្ច័យដល់ភព

### លក្ខណាទិចតុក្កៈរបស់ឧបាទាន

-គហណលក្ខណំ : មានការប្រកាន់ទុក ជាលក្ខណៈ

-អមុញ្ចនរសំ : មានការមិនព្រលែង ជាកិច្ច

-តណ្ហាទឡ្ហត្តទិដ្ឋិ បច្ចុបដ្ឋានំ : មានតណ្ហាដែលមានកម្លាំង និងមានការឃើញខុស ជាផល

-តណ្ហា បទដ្ឋានំ : មានតណ្ហា ជាហេតុជិត ។

ឧបាទានដែលជាបច្ច័យដល់ភព ក៏បានដល់ ឧបាទាន ៤ មានសេចក្តីដូចតទៅនេះ

ភព ដែលជាបច្ចយុប្បន្នៈរបស់ឧបាទាន បានដល់ ភព ២ យ៉ាងគឺ កម្មភព ១ និង ឧបបត្តិភព ១ ។

<u>កម្មភព</u> : ការតាក់តែងឱ្យកើតបច្ចយុប្បន្នធម៌ បានដល់ កម្ម ២៩ ឬ ចេតនា ២៩ គឺ អកុសលចេតនា ១២ លោកិយកុសលចេតនា ១៧ ។

<u>ឧបបត្តិភព</u> : គឺ បច្ចយុប្បន្នធម៌ ដែលប្រាកដឡើងក្នុងភពនោះៗ ព្រោះអាស្រ័យកម្មភពជាបច្ច័យ ដូច្នោះ ឧបបត្តិភព បានដល់ លោកិយវិបាក-វិញ្ញាណ ៣២ ចេតសិក ៣៥ កម្មជរូប ១៨ ឬ ២០ ដែលជាហេតុឱ្យសត្វកើត

ក្នុង ៣១ ភូមិ និងមានការឃើញ ឮ ធុមក្លិន ដឹងរស ដឹងផោដ្ឋព្វៈ និង ការនឹកគិត តាមសមគួរដល់អត្តភាពនៃខ្លួន ។

ក្នុងភពទាំង ២ នោះ កម្មភព និងឧបបត្តិភព ជាហេតុផលដល់គ្នានឹងគ្នា បានទៀតផង គឺ

**កម្មភពជាហេតុ ឧបបត្តិភពជាផល** មានន័យថា ព្រោះបានធ្វើកម្មទុកល្អ និងអាក្រក់ ទើបប្រាកដផលឱ្យបានកើតមកមានខន្ធ ៥ ឬខន្ធ ៤ ឬខន្ធ ១ តាមសមគួរដល់កម្មនោះៗ ការបាននូវខន្ធនេះឯងជា ឧបបត្តិភព ។

**ឧបបត្តិភពជាហេតុ កម្មភពជាផល** មានន័យថា កាលបើមានខន្ធ ៥ ខន្ធ ៤ ជាឧបបត្តិភពជាហេតុ ទើបធ្វើឱ្យមានកម្មភព គឺ ការធ្វើកម្មល្អ ឬកម្មអាក្រក់ទាំងឡាយតាមផ្លូវ កាយ វាចា ចិត្ត ។ បើមិនមានឧបបត្តិភពហើយ ក៏មិនមានកម្មភពដែរ ។

ម្យ៉ាងទៀត សង្ខារដែលជាបច្ចយុប្បន្នៈរបស់អវិជ្ជា ជាមួយនឹងកម្មភពដែលជាបច្ចយុប្បន្នៈរបស់ឧបាទាននេះ ពោលដោយអង្គធម៌ បានដល់ចេតនា ២៩ ដូចគ្នា តែមានសេចក្ដីផ្សេងគ្នា គឺ

បើពោលដោយ **តយោអទ្ធា** (កាល ៣) ចេតនា ២៩ ដែលកើតឡើងក្នុងអតីតភព ដែលជាបច្ច័យដល់ឧបាទានក្ខន្ធក្នុងបច្ចុប្បន្នភពនេះ ឈ្មោះថា **សង្ខារ** ។

ចេតនា ២៩ ដែលកើតក្នុងបច្ចុប្បន្នភពនេះ ដែលជាបច្ច័យដល់ឧបាទានក្ខន្ធក្នុងអនាគត ឈ្មោះថា កម្មភព ។

បុព្វចេតនា ដែលកើតឡើងមុនការធ្វើកុសល អកុសល ឈ្មោះថា សង្ខារ ។

មុញ្ចនចេតនា ដែលកើតក្នុងខណៈកំពុងធ្វើកុសល អកុសល ឈ្មោះថា កម្មភព ។

## បច្ច័យ ២៤ ទាក់ទងនឹងឧបាទាន

ក-កាមុបាទានជាបច្ច័យដល់ភព ដោយអំណាច ៧ បច្ច័យ គឺ

| | | |
|---|---|---|
| ១.ហេតុ | ២.សហជាត | ៣.អញ្ញមញ្ញ |
| ៤.និស្សយ | ៥.សម្បយុត្ត | ៦.អត្ថិ |
| ៧.អវិគត | | |

ខ-ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តាវាទុបាន ជាបច្ច័យដល់ភព ក៏ដោយអំណាច ៧ បច្ច័យតាមសមគួរ គឺ

| | | |
|---|---|---|
| ១.សហជាត | ២.អញ្ញមញ្ញ | ៣.និស្សយ |
| ៤.មគ្គ | ៥.សម្បយុត្ត | ៦.អត្ថិ |
| ៧.អវិគត | | |

## អង្គទី ១០ ភព

## ភព ជាបច្ច័យដល់ ជាតិ

លក្ខណាទិចតុកៈរបស់កម្មភព

-កម្មលក្ខណោ : មានសភាពជាកម្ម ជាលក្ខណៈ

-ភាវនរសោ : មានការធ្វើឱ្យកើត ជាកិច្ច

-កុសលាកុសលបច្ចុប្បដ្ឋានោ : មានភាពជាកុសល អកុសល ជាផល

-ឧបាទានបទដ្ឋានោ : មានឧបាទាន ជាហេតុជិត ។

លក្ខណាទិចតុក្កៈរបស់ឧបបត្តិភព

-កម្មផលលក្ខណោ : មានភាពជាផលរបស់កម្ម ជាលក្ខណៈ

-ភវនរសោ : មានការកើតឡើង ជាកិច្ច

-អព្យាកតបច្ចុប្បដ្ឋានោ : មានភាពជាអព្យាកតធម៌ ជាអាការប្រាកដ

-ឧបាទានបទដ្ឋានោ : មានឧបាទាន ជាហេតុជិត ។

ក្នុងបទមុន ភព ជាបច្ចយុប្បន្នៈរបស់ឧបាទាន បានដល់ ភព ទាំង ២ ទាំងកម្មភព និងឧបបត្តិភព ។

តែក្នុងបទនេះ ភព ដែលជាបច្ច័យដល់ជាតិ បានដល់ កម្មភព តែម្យ៉ាងប៉ុណ្ណោះ ព្រោះកម្មភព ជាគ្រឿងតាក់តែងឱ្យឧបបត្តិភព គឺ ជាតិកើតឡើង ដូច្នេះ ឧបបត្តិភព គឺ ជាតិ ក៏ត្រឹមតែជាផលកើតឡើងអាស្រ័យកម្មភពនោះឯង ។

ជាតិ ដែលជាបច្ចយុប្បន្នៈរបស់កម្មភព បានដល់ ការកើតឡើងក្នុងភពថ្មីជាដំបូងរបស់លោកិយវិបាកវិញ្ញាណ ចេតសិក និងកម្មជរូប ក៏គឺ ឧបបត្តិភពក្នុង ៣១ ភូមិ មានខន្ធ ៥ ខន្ធ ៤ ខន្ធ ១ មានវចនត្ថៈថា

**ជាយន្តិ បាតុភវន្តិ ធម្មា ឯតាយាតិ ជាតិ** សង្ខារធម៌ទាំងឡាយរមែងប្រាកដឡើង អាស្រ័យធម្មជាតិណា ធម្មជាតិដែលជាហេតុនៃការប្រាកដ

ឡើងនៃសង្ខារធម៌នោះ ឈ្មោះថា **ជាតិ** ។

ពោលដោយ នាមរូប **ជាតិក៏មាន ២ គឺ នាមជាតិ** ជាការកើតឡើងនៃវិបាកនាមក្ខន្ធ ៤ និង **រូបជាតិ** ជាការកើតឡើងនៃកម្មជរូប ។

ពោលដោយកាល ជាតិមាន ៣ គឺ

**ក.បដិសន្ធិជាតិ** បានដល់ បដិសន្ធិចិត្ត ១៩ ចេតសិក ៣៥ និងកម្មជ-រូប ដែលកើតឡើងក្នុងខណៈបដិសន្ធិកាល សំដៅដល់ ការកើតឡើងជាគ្រាដំបូងក្នុងភពថ្មីរបស់សត្វទាំងឡាយ ដែលស្លាប់អំពីភពចាស់ ។

**ខ.សន្តតិជាតិ** បានដល់ ការបន្តរបស់ចិត្ត ចេតសិក រូប ក្នុងបវត្តិកាល សំដៅដល់ នាម និងរូបរបស់សត្វនោះៗ ដែលកើតឡើងតអំពីខណៈបដិសន្ធិរហូតដល់អស់ជីវិត ។

**គ.ខណិកជាតិ** បានដល់ ការកើតឡើងមួយខណៈៗ របស់ចិត្ត ចេត-សិក រូបទាំងអស់ ។

តែថា **ជាតិ** ក្នុងបទនេះ សំដៅចំពោះ **បដិសន្ធិជាតិ** ប៉ុណ្ណោះ ។

## បច្ច័យ ២៤ ទាក់ទងនឹងភព

កាលពោលដោយបច្ច័យ ២៤ ភពជាបច្ច័យដល់ជាតិ ប្រព្រឹត្តទៅបានដោយអំណាច ២ បច្ច័យ គឺ ឧបនិស្សយប្បច្ច័យ និងកម្មប្បច្ច័យ ។

## អង្គទី ១១ ជាតិ

## ជាតិ ជាបច្ច័យដល់ ជរាមរណៈ

## លក្ខណាទិចតុក្កៈរបស់ជាតិ

**-តត្ថ តត្ថ ភវេ បឋមាភិនិព្វត្តិ លក្ខណា :** មានការកើតឡើងជាគ្រាដំបូងក្នុងភពនោះៗ ជាលក្ខណៈ

**-និយ្យាតន រសា** : មានការប្រព្រឹត្តទៅ ដូចជាបង្កោនខន្ធ ៥ ក្នុងក្របខ័ណ្ឌនៃភពមួយៗ ឱ្យដល់សត្វទាំងឡាយ ជាកិច្ច

**-អតិត្តភវតោ ឥធ ឧម្មុជ្ជន បច្ចុប្បដ្ឋានា**

**វា ទុក្ខវិចិត្តត្តា បច្ចុប្បដ្ឋានា** : មានការផុសឡើងក្នុងភពនេះ ចាកអំពីភពមុន ជាផល (ឬ) មានការពេញទៅដោយទុក្ខ ជាផល

**-ឧបចិតមានរូបបទដ្ឋានា** : មាននាម រូប ដែលកើតឡើងគ្រាដំបូង ជាហេតុជិត ។

**ជាតិ ជាបច្ច័យដល់ ជរាមរណៈ** ។ ជាតិ បានដល់ វិបាកនាមក្ខន្ធ ៤ និងកម្មជរូប គឺ បដិសន្ធិចិត្ត ១៩ ចេតសិក ៣៥ និងកម្មជរូប ។

**ជរា** ជាបច្ចុយុប្បន្នះរបស់ជាតិ បានដល់ សេចក្តីចាស់ ការទ្រុឌទ្រោមរបស់វិបាកនាមក្ខន្ធ ៤ និងកម្មជរូប មានន័យថា កាលបើវិបាកនាមក្ខន្ធ ៤ និងកម្មជរូបប្រាកដឡើងហើយ រមែងមានខណៈដែលតាំងនៅ ហៅថា ឋិតិ-ខណៈ , ឋិតិខណៈរបស់វិបាកនាមក្ខន្ធ ៤ និងកម្មជរូបនេះឯង ហៅថា **ជរា** ។

**មរណៈ** ជាបច្ចុយុប្បន្នះរបស់ជាតិ បានដល់ អាការរលត់កំពុងទៅរបស់វិបាកនាមក្ខន្ធ ៤ និងកម្មជរូប មានន័យថា កាលវិបាកនាមក្ខន្ធ ៤ និងកម្មជរូបប្រាកដឡើងជាជាតិហើយ ក៏តាំងនៅដោយជួរខណៈ ហៅថា **ឋិតិ-**

**ខណៈ** តអំពីនោះរមែងមានខណៈដែលរលត់ ហៅថា **ភង្គខណៈ** , ភង្គខណៈរបស់វិបាកនាមក្ខន្ធ ៤ និងកម្មជរូប នេះឯងហៅថា **មរណៈ** ។

ន័យម្យ៉ាងទៀត ក៏ពោលថា រាប់តាំងអំពីសត្វកើតរហូតដល់ស្លាប់ ហៅថា **ជរា** ខណៈដែលកំពុងស្លាប់ ហៅថា **មរណៈ** ។

អាយុរបស់មនុស្សសម័យពុទ្ធកាល តាមប្រក្រតី មានប្រមាណ ១០០ ឆ្នាំ គឺ មានភាពជរាហើយអស់ ១០០ ឆ្នាំ ។ ក្នុង១០០ ឆ្នាំ ចាត់ជា ១០ វ័យ ឬ ១០ រយៈកាល ដូច្នេះ

១.មន្ទទសកៈ វ័យកុមារ រាប់តាំងពីកើតដល់ ១០ ឆ្នាំ នៅជាទារក គឺ ផ្ដើមរៀនអង្គុយ រៀនឈរ រៀនដើរ រៀននិយាយ លេងដី ជាដើម តាមវិស័យនៃទារក ។

២.ខិឌ្ឌាទសកៈ វ័យជំទង់ រាប់ពីអាយុ ១០ ឆ្នាំដល់ ២០ ឆ្នាំ ចូលចិត្តលេង ពេញចិត្តកន្លែងណាក៏ទៅកន្លែងនោះ ស៊ីច្រើន ដេកច្រើន លេងច្រើន ។

៣.វណ្ណទសកៈ វ័យស្រឡាញ់ខ្លួន រាប់ពីអាយុ ២០ ឆ្នាំដល់ ៣០ ឆ្នាំ ជាវ័យកំលោះ ក្រមុំ ស្រឡាញ់ភាពល្អស្អាត ត្រេកអរក្នុងអារម្មណ៍ដែលជាទីពេញចិត្ត ភ្លើតភ្លើនក្នុងអារម្មណ៍ដែលជាទីតាំងនៃតម្រេក មិននឹងដល់សេចក្ដីទុក្ខលំបាកណាៗ ឡើយ ។

៤.ពលទសកៈ វ័យមានកម្លាំង រាប់ពីអាយុ ៣០ ឆ្នាំដល់ ៤០ ឆ្នាំ គឺប្រកបដោយកម្លាំងមាំមួន មានការគិតច្រើន និងពេញចិត្តដល់ការងារ ។

៥.បញ្ញាទសកៈ វ័យមានបញ្ញា រាប់ពីអាយុ ៤០ ឆ្នាំដល់ ៥០ ឆ្នាំ

មានសតិគ្រប់គ្រង ជាវ័យមានបញ្ញាឆ្លាតឈ្លាស ស្គាល់ហេតុ ស្គាល់ផល ស្គាល់គុណ ស្គាល់ទោស ដឹងប្រយោជន៍ និងមិនមែនប្រយោជន៍ ។

៦.**ហានិទសកៈ** វ័យវិនាស រាប់ពី ៥០ ឆ្នាំដល់ ៦០ ឆ្នាំ ទាំងកម្លាំងកាយ និងកម្លាំងបញ្ញា ក៏ផ្ដើមថយចុះ ទន់ខ្សោយទាំងកម្លាំងកាយ និងចិត្ត ។

៧.**បព្ភារទសកៈ** វ័យជរា រាប់ពី ៦០ ឆ្នាំដល់ ៧០ ឆ្នាំ មានការចុករោយ ភ្នែកក៏ស្រវាំង ត្រចៀកក៏ធ្ងន់ទៅ និងមានសភាពភ្លេចភ្លាំងទៅៗ ។

៨.**វង្កទសកៈ** វ័យខ្នងកោង រាប់ពីអាយុ ៧០ ឆ្នាំដល់ ៨០ ឆ្នាំ គឺ មានខ្នងកោងចុះ ទៅណាមកណា ក៏ត្រូវប្រើឈើច្រត់ជាជំនួយ ហៅថា មានជើង ៣ ភ្នែក ៤ ធ្មេញ ២ ជាន់ មានសភាពទ្រុឌទ្រោម លំបាកខ្លាំង ។

៩.**មោមូហទសកៈ** វ័យវង្វេង រាប់ពីអាយុ ៨០ ឆ្នាំដល់ ៩០ ឆ្នាំ គឺ អ្វីៗ ដែលធ្លាប់ចងចាំ ក៏ត្រូវភ្លេចអស់ និយាយក៏ខុស វង្វេងវង្វាន់ ស៊ីហើយក៏ថាមិនទាន់បានស៊ី ជាដើម ។

១០.**សយនទសកៈ** វ័យដេក រាប់ពីអាយុ ៩០ ឆ្នាំដល់ ១០០ ឆ្នាំ សូម្បីនឹងក្រោកក៏មិនរួច មានការស៊ីដេក បន្ទោបង់ដេក និងរង់ចាំតែសេចក្ដីស្លាប់ប៉ុណ្ណោះ ។

ន័យម្យ៉ាងទៀត ក៏ប្រៀបមនុស្សដូចជាសត្វតិរច្ឆាន ៤ ពួក ដែលជាគតិ ដែលគួរពិចារណា

-វ័យក្មេង ឧបមាដូច ជ្រូក មានតែស៊ី និងដេក ស៊ីច្រើន ដេកច្រើន

-វ័យកណ្ដាល ឧបមាដូច គោ ត្រូវធ្វើការងារ ប្រឹងប្រែងក្នុងអាជីព

-វ័យចាស់ ឧបមាដូច សុនខ ត្រូវនៅចាំផ្ទះ មើលកូនចៅ

-វ័យជរា ឧបមាដូច ស្វា ដែលកូនចៅត្រូវចាំរក្សា

**បច្ច័យ ២៤ ទាក់ទងនឹងជាតិ**

ពោលដោយបច្ច័យ ២៤ តាមអភិធម្មន័យ ពោលថា ជាតិជាបច្ច័យដល់ជរាមរណៈមិនបាន ព្រោះជរា ក៏ជាឋិតិខណៈរបស់ជាតិ , មរណៈ ក៏បានដល់ភង្គខណៈរបស់ជាតិ នោះឯង ។

តាមសុត្តន្តន័យ ជាតិជាបច្ច័យដល់ជរាមរណៈ ក៏ដោយអំណាច ១ បច្ច័យប៉ុណ្ណោះ គឺ បកតូបនិស្សយប្បច្ច័យ ។

## អង្គទី ១២ ជរាមរណៈ

ជរាមរណៈនេះ ជាអង្គទី ១២ មិនជាបច្ច័យឱ្យកើតបច្ចយុប្បន្នធមិ តាមន័យនៃបដិច្ចសមុប្បាទនេះ ដែលមិនជាបច្ច័យព្រោះហេតុណានោះ ក៏បានពោលហើយនោះឯង ។

### លក្ខណាទិចតុក្កៈរបស់ជរាមរណៈ

<u>ជរា</u>

-**ខន្ធបរិបាកលក្ខណា** : មានការចាស់របស់ខន្ធ ដែលប្រាកដហើយក្នុងបច្ចុប្បន្នភព ជាលក្ខណៈ

-**មរណូបនយនរសា** : មានការនាំចូលទៅជិតសេចក្ដីស្លាប់ ជាកិច្ច

-**យោព្វន្នវិនាសបច្ចុប្បដ្ឋានា** : មានការទម្លាយវ័យដែលល្អ ជាផល

**-បរិបច្ចុមានរូបបទដ្ឋានា** : មានរូបដែលកំពុងចាស់ ជាហេតុជិត ។

<u>មរណៈ</u>

**-ចុតិលក្ខណំ** : មានការឃ្លាតចាកភពកំពុងប្រាកដ ជាលក្ខណៈ

**-វិយោគរសំ** : មានការឃ្លាតចាកវត្ថុដែលមានជីវិត និងមិនមានជីវិតទាំងពួង ដែលធ្លាប់ដឹងក្នុងភពនេះ ជាកិច្ច

**-គតិវិប្បវាសបច្ចុប្បដ្ឋានំ** : មានការប្រាសទៅអំពីទីនៅក្នុងភពចាស់ ជាផល

**-បរិភិជ្ជមាននាមរូបបទដ្ឋានំ** : មាននាមរូបដែលកំពុងរលត់ ជាហេតុជិត ។

សភាព **ជរា មរណៈ** ដែលបានដល់ ការចាស់គ្រាំគ្រា និងការកំពុងរលត់របស់វិបាកនាមក្ខន្ធ ៤ និងកម្មជរូប ក៏ព្រោះអាស្រ័យជាតិនោះឯង

**ជរា** មាន ២ គឺ រូបជរា និង នាមជរា

**រូបជរា** សំដៅដល់ការជរារបស់រូបទៅតាមវ័យ មានអាការប្រាកដឱ្យឃើញដោយភ្នែក ដូចជា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ ខ្នងកោងជាដើម នេះឈ្មោះថា **វយោវុទ្ធិជរា** ដែលជាបញ្ញត្តិ ជាជរាប្រាកដ (បាកដ-ជរា) ជាជរាមិនបិទបាំង (អប្បដិច្ឆន្នជរា) ។

ម្យ៉ាងទៀត បរមត្ថជរា ឬ ខណិកជរា បានដល់ ឋិតិខណៈរបស់រូបជាជរាដែលបិទបាំង (បដិច្ឆន្នជរា) ជាជរាមិនប្រាកដ គឺ មិនអាចមើលនឹងភ្នែកឃើញបាន (អបាកដជរា) ។

**រូបជរា** ចែកបានជា ២ ទៀត គឺ **អភិក្កមជរា** ចាស់ឡើងៗ និង **បដិ-**

**ក្កមជរា** ប្រែប្រួល ។

បុគ្គលនៅក្នុងវ័យទី ១ មន្ទទសកៈ រហូតដល់ វ័យទី ៤ ពលទសកៈ ហៅថា **អភិក្កមជរា** គឺ កំពុងចាស់ឡើង ។

ចំណែកកន្លងវ័យទី ៤ ទៅ ហៅថា **បដិក្កមជរា** គឺ ប្រែប្រួល ។

**នាមជរា** បានដល់ ឋិតិខណៈរបស់នាមធម៌ គឺ បរមត្ថជរា ឬ ខណិក-ជរា ឬ បដិច្ឆន្នជរា នោះឯង ជាជរាដែលមើលដោយភ្នែកមិនឃើញ ។

<u>មរណៈ</u> ក៏មាន ២ យ៉ាងគឺ រូបមរណៈ និងនាមមរណៈ

**រូបមរណៈ** សំដៅដល់ការរលត់ទៅរបស់រូប ហៅថា ភង្គខណៈ ក្នុងទីនេះបានដល់ សម្មតិមរណៈ ដែលហៅថា មនុស្សស្លាប់ សត្វស្លាប់ជាដើម ។

**នាមមរណៈ** គឺ ការរលត់របស់នាមក្ខន្ធ ៤ ហៅថា ភង្គខណៈ ។

សរុបដោយសង្ខេប គឺ

ឧប្បាទខណៈ របស់វិបាកនាមក្ខន្ធ ៤ និងកម្មជរូប ឈ្មោះថា ជាតិ

ឋិតិខណៈ របស់វិបាកនាមក្ខន្ធ ៤ និងកម្មជរូប ឈ្មោះថា ជរា

ភង្គខណៈ របស់វិបាកនាមក្ខន្ធ ៤ និងកម្មជរូប ឈ្មោះថា មរណៈ

ពាក្យថា មរណៈ ឬ ស្លាប់ នេះ មានពាក្យប្រើច្រើនយ៉ាង ដូចជា

| | |
|---|---|
| **-ចុតិ** | ស្លាប់ |
| **-ចវនតា** | ការឃ្លាតទៅ |
| **-ភេទោ** | ការបែកធ្លាយ |
| **-អន្តរធាន** | ការវិនាសទៅ |

| | |
|---|---|
| **-មច្ចុ** | សេចក្តីស្លាប់ |
| **-កាលកិរិយា** | ការធ្វើកាល |
| **-ខន្ធានំ ភេទោ** | ការបែកធ្លាយនៃខន្ធ |
| **-កលេវរស្ស និក្ខេបោ** | ការលះបង់សរីរៈ រាងកាយ |
| **-ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ** | ការដាច់នៃជីវិតិន្ទ្រិយ |

នេះជាសេចក្តីសង្ខេបក្នុងបដិច្ចសមុប្បាទន័យ ចំណែក **សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ និងឧបាយាសៈ** មិនបានរៀបរាប់ទេ សូមសាធុសប្បុរសស្វែងរកសិក្សាបន្ថែមចុះ ។